September-2007 II.qxd 9/21/2007 2:56 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក
ទូរស័ព្ទ: ០២៣ ២២៤ ១២០

# អ្នកនាំសារ
The Messenger

០២

ឆ្នាំទី១ ថ្ងៃទី១៥-៣០ កញ្ញា ២០០៧- ច្បាប់អនុញ្ញាតរបស់ក្រសួងព័ត៌មានលេខ ១៨៣ ពមប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៧

## មាតិកាសំខាន់ៗ



ការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី
ទំព័រ ៣



ជនពិការនៅ តែរងទុក្ខ និងខ្វះខាត
ទំព័រ ៩

សត្វអន្ទង់ គេអាចចិញ្ចឹមបាន
ទំព័រ ៤

# អនីតិជនទណ្ឌិតទទួលបានការអប់រំអក្ខរកម្ម



ទំព័រទី៦...

យានដ្ឋាន For you
for you Garage
មានទទួលជួសជុលរថយន្តគ្រប់ប្រភេទ
All Kinds of Repairing Services
សូមមេត្តាជួយផ្តល់ឱកាសដល់យុវជនក្រីក្រដែលគ្មានលទ្ធភាពទទួលការអប់រំនៅសាលា។ សូមអរគុណ!
Tell: 012 377 460 E-mail: philong2007@gmail.com
អាសយដ្ឋាន : ផ្លូវជាតិលេខ ៥ គីឡូម៉ែត្រលេខ ៨

កម្មវិធីវិទ្យុ
អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។
កំពង់ធំ : FM 107.3 Mhz ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍ ។
កំពង់ចាម : FM 100.5 Mhz ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ ។
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍ ។

September-2007 II.qxd 9/21/2007 2:56 PM Page 2



# ប្រជារាស្ត្រ និងរដ្ឋ

នៅក្នុងប្រទេសមួយ មានរដ្ឋាភិបាល ត្រូវតែមានប្រជាជន ហើយមានប្រជាជនត្រូវតែមានការគ្រប់គ្រងជាផ្លូវរដ្ឋ មានអ្នកណែនាំ ឬដឹកនាំដើម្បីឆ្ពោះទៅរកភាពសុខដុម និងវឌ្ឍនភាព។

រដ្ឋាភិបាលមួយប្រកាន់យកនូវគោលការដឹកនាំតាមបែបលិទ្ធិប្រជាធិបតេយ្យ គឺរដ្ឋាភិបាលនោះកើតចេញពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ហើយរដ្ឋាភិបាលនោះយកប្រជារាស្ត្រជាធំ មិនជិះជាន់ មិនកៀបសង្កត់ គឺផ្តល់សិទ្ធិដ៏ទូលំទូលាយ និងផ្តល់សេរីភាពគ្រប់គ្រាន់ដល់ពលរដ្ឋរបស់ខ្លួន។

ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ដែលរដ្ឋាភិបាលកើតចេញពីការបោះឆ្នោតរបស់ប្រជាជនកម្ពុជានោះបានផ្តល់នូវសេរីភាពយ៉ាងពេញលេញដល់ប្រជាជន ដូចជាសេរីភាពក្នុងការបញ្ចេញមតិយោបល់ សេរីភាពក្នុងការរស់នៅប្រកបដោយជីវភាពសមរម្យ និងសេរីភាពក្នុងជំនឿសាសនាជាដើម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សិទ្ធិ និងសេរីភាពទាំងនេះក៏ត្រូវតែស្ថិតនៅក្នុងបទដ្ឋានមួយនៃច្បាប់ដែរ គឺដើម្បីរក្សាឱ្យបាននូវសេចក្តីថ្លៃថ្នូរ ស្ថិរភាព សន្តិភាព និងសណ្តាប់ធ្នាប់សង្គម។ ព្រះរាជាណាចក្រកម្ពុជាទើបបានឆ្លងផុតពីសង្គ្រាមដ៏រ៉ាំរ៉ៃជាងបីទសវត្សរ៍។ សង្គ្រាមបានធ្វើឱ្យប្រទេសជាតិជួបនូវការវិនាសអន្តរាយលើគ្រប់វិស័យ ជាពិសេស គឺប្រជាជនខ្មែរជាង ២លាននាក់ត្រូវបាត់បង់។ សង្គ្រាមបានបន្សល់នូវស្ត្រីមេម៉ាយ កូនកំព្រា ជនពិការ និងភាពក្រីក្រ ដែលជាបន្ទុកយ៉ាងធ្ងន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជាយើង។ រដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតរបស់ប្រជាជនក្នុងរយៈពេល៣អាណត្តិនេះបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការកសាង និងអភិវឌ្ឍប្រទេស មានការស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ និងឧបរ្សាហកម្ម-ល- ក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ប៉ុន្តែការខិតខំទាំងនេះមិនទាន់គ្រប់គ្រាន់ និងឆ្លើយតបទៅនឹងអ្វីដែលជាតម្រូវការទេ។ ប្រជាជនមួយភាគស្ថិតក្នុងភាពក្រីក្រនៅឡើយ កសិករមួយចំនួនត្រូវគេរំលោភយកដី តុលាការអយុត្តិធម៌ និងភាពគ្មានការងារធ្វើកំពុងកើនឡើង-ល-។ ដូច្នេះតើយើងទាំងអស់ត្រូវធ្វើដូចម្តេច? ត្រូវបន្ទោសរដ្ឋាភិបាល ឬយ៉ាងណា? ទេ! មិនមែនទេ គឺយើងត្រូវរួមគ្នាធ្វើការយ៉ាងសកម្មរវាងរាជរដ្ឋាភិបាល និងប្រជាជនដើម្បីធ្វើយ៉ាងណា កុំឱ្យមានគម្លាតនៃភាពមានបានខ្លាំងពេករវាងអ្នកមាន និងអ្នកក្រីក្រ។

**អ្នកនាំសារ**



## តើមានរូបអ្វីសម្រាប់លេខនេះ...?



ការអនុវត្តន៍ច្បាប់ចរាចរណ៍នៅតាមដងផ្លូវមិនទាន់បានទូលំទូលាយនៅឡើយ។ ប្រជាពលរដ្ឋខ្មែរត្រូវការស្វែងយល់បន្ថែមពីច្បាប់នេះដើម្បីសុវត្ថិភាពខ្លួន



ប្រទេសកម្ពុជានៅតែមានកុមារកំព្រា និងក្រីក្រជាច្រើន ដែលពួកគេខ្វះមធ្យោបាយចិញ្ចឹមជីវិត និងទទួលការរៀនសូត្រ តើស្ថាប័ន អង្គការ ឬនរណាម្នាក់អាចមានគោលនយោបាយ ឬផ្តល់អ្វីដែលជាទីសង្ឃឹមថ្មីដល់ពួកគេបាន?



ឆ្នាំនេះពេលភ្លៀងធំ ធ្វើឱ្យផ្លូវនៅរាជធានីភ្នំពេញត្រូវលិចទឹក ប្រជាពលរដ្ឋត្រូវពិបាកធ្វើដំណើរយ៉ាងខ្លាំង



លោកតាអូសស៊ីក្លូរបស់គាត់កណ្តាលទឹកដោយសារបណ្តាញលូមានភាពតូចចង្អៀត ធ្វើឱ្យទឹកហូរមិនទាន់

Photographed by L. Sovanna & S. Philong





# ប្រជាពលរដ្ឋសូមអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកថ្មីដោយតម្លាភាព

បច្ចុប្បន្ននេះ គ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជាបានក្លាយទៅជាវិញ្ញាសាចម្បង និងជាការព្រួយបារម្ភធំបំផុតរបស់រាជរដ្ឋាភិបាល ដែលបានចាត់ទុកជាគ្រោះថ្នាក់ដ៏ធំមួយក្នុងចំណោមគ្រោះថ្នាក់ដទៃៗ។ ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី គឺសំដៅធានាឱ្យបាននូវសុវត្ថិភាព នៅក្នុងពេលធ្វើដំណើរសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដែលប្រើប្រាស់ផ្លូវសាធារណៈនៅទូទាំងប្រទេស។

ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មានប្រសាសន៍ថា: គ្រោះថ្នាក់ចរាចរណ៍កើតឡើងបណ្តាលមកពីកត្តាបីសំខាន់ គឺកត្តាមនុស្ស កត្តាយានយន្ត និងកត្តាផ្លូវថ្នល់។ កត្តាមនុស្ស មានចំនួនដល់ ៩៤% អ្នកប្រើប្រាស់ផ្លូវពុំគោរពច្បាប់ចរាចរណ៍ បើកបរល្បឿនហួសកំណត់ ឬបើកបរដោយធ្វេសប្រហែស និងបើកបរមានជាតិស្រវឹងជាដើម។ កត្តាយានយន្តមានចំនួន ៣% ពីព្រោះម្ចាស់យានយន្តទាំងអស់នោះ មិនបានធ្វើការថែទាំត្រួតពិនិត្យនូវលក្ខណៈបច្ចេកទេស តាមច្បាប់កំណត់ ធ្វើឱ្យអ្នកបើកបរមិនអាចបញ្ជាយានជំនិះបាននៅពេលកំពុងបើកបរដូចជា ខូចហ្វ្រាំង ឬម៉ាស៊ីន បែកកង់ ភ្លើងបំភ្លឺមិនឆេះ និងការប្រើប្រាស់ភ្លើងមិនបានត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេសជាដើម។រីឯកត្តាផ្លូវថ្នល់ មាន ១% ដោយសារហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន មិនទាន់បានសមស្របទៅនឹងលក្ខណៈបច្ចេកទេសដូចជា: ផ្លូវមានជង្ហុក ផ្លូវកោងខ្លាំង ផ្លូវធំ ប៉ុន្តែមានស្ពានតូចចង្អៀត និងមិនទាន់មានផ្លាកសញ្ញាចរាចរណ៍គ្រប់គ្រាន់។ ក្រៅអំពីនេះ ក៏មានកត្តាផ្សេងៗ រួមផ្សំ ចំនួន២% ទៀតផងដែរ ដូចជា កត្តាធម្មជាតិ និងភ្លៀងរអិលជាដើម។

ទាក់ទិនបញ្ហាខាងលើនេះលោក មាស ចាន់ឌី ជាមន្ត្រីកម្មវិធីសុវត្ថិភាពចរាចរណ៍របស់អង្គការជនពិការអន្តរជាតិ មានប្រសាសន៍ផងដែរថា: គ្រប់អ្នកបើកបរយានយន្តនៅលើផ្លូវសាធារណៈទាំងអស់គឺត្រូវគោរពច្បាប់ និងត្រូវមានប័ណ្ណបើកបរដែលកំណត់ដោយច្បាប់។ ក្នុងករណីអ្នកបើកបរមានប័ណ្ណបើកបររថយន្តអាចប្រើប្រាស់សម្រាប់ម៉ូតូដែលមានកម្លាំងម៉ាស៊ីន១២៥សេះ ចុះក្រោម (កម្រិតក១)។ តែគេមិនអាចប្រើប្រាស់ចំពោះម៉ូតូមានកម្លាំងម៉ាស៊ីនចាប់ពី១២៥សេះឡើងលើនោះឡើយ។ ដូច្នេះ គឺត្រូវទាមទារ ឱ្យមានប័ណ្ណបើកបរម៉ូតូដែល មានកម្លាំងម៉ាស៊ីនចាប់ពី១២៥សេះឡើង (កម្រិតក២) ផ្សេងមួយទៀត ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ លោកមានប្រសាសន៍ទៀតដែរថា: "ទោះបីក្នុងគ្រួសារមានសមាជិកប៉ុន្មាននាក់ក៏ដោយ គឺឱ្យតែបញ្ជាយានយន្តនៅលើផ្លូវសាធារណៈត្រូវតែមានប័ណ្ណបើកបរជាកំហិត ដែលវាកំណត់ដោយច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។"

កំពុងអង្គុយរង់ចាំម៉ូយ នៅទល់មុខផ្សារកណ្តាល លោកប៊ូ សារឿន ជាអ្នករត់ម៉ូតូឌុបមកពីព្រៃវែង មានប្រសាសន៍ចាប់អារម្មណ៍ អំពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនេះថា ក្នុងនាមលោកគឺជាពលរដ្ឋខ្មែរម្នាក់ លោករីករាយនឹងអនុវត្តតាមអ្វីដែលច្បាប់បានកំណត់ដើម្បីមានសុវត្ថិភាពក្នុងការធ្វើដំណើរផ្ទាល់ខ្លួន និងអ្នកដទៃទៀត។ ការគោរពច្បាប់គឺជាសុជីវធម៌ថ្លៃថ្នូរ និងជាកាតព្វកិច្ចរបស់ពលរដ្ឋម្នាក់ៗ។ ប៉ុន្តែលោកក៏បានសំណូមពរសូមឱ្យមានការគោរពច្បាប់ប្រកបដោយតម្លាភាព រវាងអ្នកក្រីក្រ និងអ្នកមានទ្រព្យសម្បត្តិ ជាពិសេសមន្ត្រីអនុវត្តន៍ច្បាប់ ក៏ត្រូវសូមគោរពច្បាប់នេះឱ្យបានទូលំទូលាយផងដែរ។

ដើម្បីផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនេះឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ។ លោក ប៉ូ សំណាង ប្រធានមជ្ឈមណ្ឌលវប្បធម៌ជាតិ និងសីលធម៌សង្គមមានប្រសាសន៍ថា: "មជ្ឈមណ្ឌលវប្បធម៌ជាតិ និងសីលធម៌សង្គម មានការផ្សព្វផ្សាយសៀវភៅពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនេះ និងចែកជូនដោយឥតគិតថ្លៃទៅដល់ប្រជាពលរដ្ឋដែលធ្វើដំណើរនៅតាមផ្លូវ ដូចជា តាមភ្លើងស្តុបឋានសួគ៌ ភ្លើងស្តុបអំបាសាឌ័រ និងភ្លើងស្តុបមន្ទីរពេទ្យព្រះអង្គឌួងជាដើម។

សូមបងប្អូនប្រជាពលរដ្ឋរង់ចាំទទួលដោយពុំគិតថ្លៃពីភ្នាក់ងារ ដែលបម្រើជូន នៅតាមភ្លើងស្តុបទាំង៣ ដូចបានរៀបរាប់នៅខាងលើ។ កម្មវិធីនេះប្រព្រឹត្តទៅនៅថ្ងៃច័ន្ទទី ០១ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ៧:៣០នាទីព្រឹក។

**ឡុង សម្ផស្ស**




Photo: L. Sovanna





Photo: L. Sovanna

## ច្បាប់! ចរាចរណ៍ផ្លូវគោក

**សេដ្ឋកិច្ចសង្គមមានការវិវឌ្ឍទៅមុខ ចំនួនប្រជាជន និងយានយន្តប្រើប្រាស់ផ្លូវថ្នល់កាន់តែកើនមិនឈប់ឈរនោះ ធ្វើឱ្យចរាចរណ៍ចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ និងធ្វើឱ្យប្រជាជនស្លាប់ និងពិការជារៀងរាល់ថ្ងៃ។ ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ អ្នកនាំសារ សូមចុះផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ:**

គ្រប់យានជំនិះដែលមានចលនានៅលើផ្លូវថ្នល់ត្រូវមានអ្នកបើកបរ។

**មាត្រា ៥.**

ដើម្បីអនុវត្តច្បាប់ចរាចរណ៍នេះពាក្យខាងក្រោមត្រូវកំណត់និយមន័យដូចតទៅ:

ពាក្យថា ផ្លូវថ្នល់ ហៅកាត់ថាផ្លូវ គឺជាទំហំទាំងមូលនៃទ្រូងផ្លូវរួមជាមួយជាយផ្លូវ ឬចិញ្ចើមផ្លូវ

ពាក្យថាទ្រូងផ្លូវ គឺជាផ្នែកមួយនៃផ្លូវទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍

ពាក្យថា ជាយផ្លូវ គឺជាផ្នែកសងខាងនៃទ្រូងផ្លូវ ដែលនៅក្រៅពីប្រជុំជន ហើយអាចចតយានជំនិះនៅទីនោះបានក្នុងករណីចាំបាច់

ពាក្យថា ចិញ្ចើមផ្លូវ គឺជាជាយផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់អ្នកថ្មើរជើងធ្វើដំណើរ ប៉ុន្តែមិនអាចចតយាន ជំនិះនៅទីនោះបានទេ

ពាក្យថា គន្លងផ្លូវ គឺជាចំណែកមួយនៃទ្រូងផ្លូវ ខ័ណ្ឌដោយគំនូសដាច់ៗ ឬគំនូសបង្ហូតតាមបណ្តោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ

ពាក្យថា ទីប្រជុំជន គឺជាទីកន្លែងដែលមានអគារ ឬគេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញ ឬចូលនៅទីនោះ មាន-ដាក់ផ្លាកសញ្ញាឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬឈ្មោះទីប្រជុំជន ដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ ការចេញពីទីប្រជុំជនតាមដងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន

**សូមតទៅលេខក្រោយ...**

**ការស្លៀកពាក់ឱ្យបានសមរម្យនៅក្នុងពិធីផ្សេងៗ ជាករណីចាំបាច់ណាស់សម្រាប់យុវនារីគ្រប់ៗរូប បង្ហាញអំពីសោភ័ណភាពរបស់ខ្លួនចំពោះមនុស្សជាច្រើននៅជុំវិញ និងក្នុងសង្គម។ ខាងក្រោមនេះជាការណែនាំមួយចំនួននៅក្នុងការស្លៀកពាក់ :**

# ការស្លៀកពាក់ក្នុងពិធីផ្សេងៗ



រូបលម្អ : សម្លៀកបំពាក់ចូលរួមពិធីមង្គលការកែច្នៃយ៉ាងស្អាតសមរម្យ

Photo: Fr. Omer Giraldo

**ក្នុងពិធីមង្គលការ**

សម្លៀកបំពាក់ចូលរួមនៅក្នុងមង្គលការត្រូវប្រើសំពត់ដែលធ្វើនៅស្រុកខ្មែរ ដូចជាហូល ផាមួង អន្លូញ លឿក-ល-។ សំពត់អស់ទាំងនេះ បើនាងកញ្ញាយកមករចនា(កាត់) ប្រើប្រាស់តាមរបៀបទាន់សម័យនិយម ឃើញថា ល្អសមរម្យលើសសំពត់មកពីបរទេសទៅទៀត បើនាងកញ្ញាស្លៀកពាក់ទៅ គេក៏អាចសម្គាល់ថា នាងកញ្ញាជាស្ត្រីមានលក្ខណៈពេញជានារីខ្មែរ ហើយមានកិត្តិយសដ៏ខ្ពង់ខ្ពស់ផង ជាពិសេសទៀតនោះ គឺនាងកញ្ញាបានជួយលើកស្ទួយសេដ្ឋកិច្ចជាតិយើងឱ្យកាន់តែរីកចម្រើនលូតលាស់ទ្វេឡើង ។ មិនតែប៉ុណ្ណោះនាងកញ្ញាក៏បានចំណេញថវិកាដោយមិនចាំបាច់ទៅទិញសំពត់បរទេសមកប្រើប្រាស់ឡើយដែលភាគច្រើនមានតម្លៃថ្លៃផង ។

**ក្នុងពិធីរាត្រីសមោសរ**

នាងកញ្ញាទាំងឡាយត្រូវជ្រើសរើសក្រណាត់ណាដែលមានចម្រុះសសៃខ្សែសយ ឬក៏មានពណ៌ភ្លឺ ចំពោះអាវ និងសំពត់ត្រូវការយកពណ៌ប្រហាក់ប្រហែលគ្នា ឬក្រណាត់តែមួយពណ៌ក៏បានដោយកាត់ជាឈុតវែង ឬខ្លីតាមការចូលចិត្ត ។ ចំណែកអាវត្រូវបើកកធំ ឬស្មាតូចតាមការចូលចិត្ត និងការពេញនិយមទៅតាមសម័យរបស់ខ្លួន ។ មានអ្នកខ្លះ គេកាត់អាវគ្មានស្មាភ្ជាប់ នឹងសំពត់វែងរហូតដល់កែងជើងតែម្តង ហើយប្រើក្រម៉ាស្តើង ដែលមានពណ៌ខ្ចីជាងសំពត់ ឬក៏អាវបន្តិចដណ្តប់ពីលើក៏ល្អម្យ៉ាងដែរ ។ សម្លៀកបំពាក់នេះត្រូវប្រើទៅតាមពណ៌ថ្ងៃ និងស្បែកជើងត្រូវប្រើកែងខ្ពស់ ទើបឃើញល្អ ។

**ពណ៌ប្រើប្រចាំថ្ងៃ**

**ការស្លៀកពាក់ប្រចាំថ្ងៃមិនមែនយើងត្រូវស្លៀកពាក់តាមចិត្តរបស់យើងនោះទេ ដើម្បីឱ្យមានសោភ័ណភាព នាងកញ្ញាត្រូវធ្វើការជ្រើសរើសពណ៌ឱ្យបានត្រឹមត្រូវតាមថ្ងៃដូចជា : ថ្ងៃអាទិត្យពណ៌ក្រហមចាស់ ឬខ្ចី ថ្ងៃចន្ទពណ៌លឿងទុំ ថ្ងៃអង្គារពណ៌ស្វាយ ថ្ងៃពុធពណ៌ស៊ីលៀប ថ្ងៃព្រហស្បតិ៍ពណ៌បៃតង ឬត្រួយចេកខ្ចី ថ្ងៃសុក្រពណ៌ខៀវ និងថ្ងៃសៅរ៍ពណ៌ព្រឹងទុំ ឬហៅ (ពណ៌និល)។**

**សម្លៀកបំពាក់ថ្ងៃធម្មតា**

ពេលព្រឹក គួរត្រូវប្រើអាវបើកក ឬអាវកជិតមានដៃ ។ សំពត់ត្រូវស្លៀកខ្លីរើសយកសំពត់ដែលមានពណ៌ស្រគាំ(ក្រម៉ៅ) ។ នៅពេលល្ងាច ត្រូវប្រើអាវដៃខ្លី កធំ កមូល ឬកជ្រុងតាមការចូលចិត្តរបស់ម្នាក់ៗ ។ ការប្រើក្រណាត់ត្រូវគួររើសទៅតាមរដូវ មិនគួរយកអាវនីឡុងមកពាក់នៅរដូវក្តៅទេ ដែលវាជាហេតុបណ្តាលឱ្យស្ទះខ្យល់ចេញចូលអាចបង្កើតទៅជារោគខ្យល់ចាប់ ។

**ការស្លៀកពាក់នៅផ្ទះ**

សម្លៀកបំពាក់បែបនេះ មានដូចជាសារុង និងពាក់អាវសង្រែកជាដើម ដែលសម្លៀកបំពាក់បែបនេះស្លៀកបានតែនៅក្នុងផ្ទះប៉ុណ្ណោះ កុំគប្បីស្លៀកវាចេញមកក្រៅរបង ឬឈរនៅតាមផ្លូវមុខផ្ទះ ឬដើរលំហែរហេតរហូតតាមមាត់ទន្លេ និងទីកន្លែងផ្សេងៗ នោះឡើយ ។ បើកំពុងស្លៀកពាក់បែបនេះប្រកបការងារនៅផ្ទះ ហើយមានភ្ញៀវចម្លែកមកលេង មុននឹងទៅទទួលគេសូមយកអាវក្រៅមកពាក់ជាមុនសិន ពីព្រោះបើទៅទទួលភ្ញៀវទាំងសម្លៀកបំពាក់ដដែលនោះនឹងនាំឱ្យខូចចរិយាថ្លៃថ្នូររបស់ស្ត្រី ហើយអាចឱ្យភ្ញៀវសម្គាល់មកលើយើងថា ជាមនុស្សខ្ជីខ្ជាខ្ជះសុជីវធម៌ក្នុងការស្លៀកពាក់ ។

**អ្នកនាំសារ**



# សត្វអន្ទង់ គេអាចចិញ្ចឹមបាន

**ដើម្បីលើកស្ទួយជីវភាព ប្រជាកសិករអាចធ្វើការងារជាច្រើន។ ការចិញ្ចឹមសត្វដែលមិនសូវមានលក់នៅលើទីផ្សារ អាចធ្វើឱ្យបងប្អូនកសិករយកចំណូលបានច្រើនដូចជាសត្វអន្ទង់ជាដើម។ ប៉ុន្តែបញ្ហាចម្បង គឺបងប្អូនត្រូវស្វែងយល់អំពីបច្ចេកទេសចិញ្ចឹមតាមអ្នកឯកទេសជំនាញដើម្បីឱ្យការចិញ្ចឹមបានទទួលនូវទិន្នផលល្អ។**



កសិករត្រូវធ្វើឱ្យភក់ម៉ត់ល្អ កុំឱ្យអន្ទង់លូនទៅមករលាត់ស្បែក

Photo: DR

តាមប្រសាសន៍របស់លោករាជ សុភាព អនុបណ្ឌិត និងអ្នកជំនាញខាងវារីវប្បកម្មនៅអង្គការសេដាក បានឱ្យដឹងអំពីបច្ចេកទេសខ្លះៗនៃការចិញ្ចឹមអន្ទង់ដូចតទៅ :

**ការរៀបចំកន្លែង**

កសិករអាចចិញ្ចឹមអន្ទង់នៅក្នុងអាងស៊ីម៉ង់ត៍ ឬពាង ក្រាលកៅស៊ូនៅបាត ។ គាត់អាចសង់អាងនៅទីស្រឡះ មានដើមឈើ មានម្លប់ខ្លះៗ ស្ងប់ស្ងាត់ និងគ្មានសំឡេងរំខាន ។ សង់អាងរួច គាត់ត្រូវដាក់ទឹកកំបោរត្រាំពី៣ ទៅ៥ថ្ងៃ ដើម្បីកាត់ក្លិនស៊ីម៉ងត៍ ។ ក្នុងទឹកមួយម៉ែត្រគីប ត្រូវដាក់កំបោរកន្លះគីឡូ ។ ពេលបូមទឹកចេញ ត្រូវលាងអាងដាក់ហាលថ្ងៃ ។ ជម្រកក្នុងអាងត្រូវរៀបចំជា ៤ស្រទាប់ :

ស្រទាប់ទី១ ដាក់ដីភក់បាតបឹងឬដីដំបូករែងឱ្យម៉ត់ កម្រាស់ ១តឹក (១០សង់ទីម៉ែត្រ) ។ ស្រទាប់ទី២ កម្រាស់ ១តឹក ដាក់លាមកមាន់និងលាមកជ្រូកស្ងួតលាយបញ្ចូលគ្នាស្មើ ។ ស្រទាប់ទី៣ ក៏កម្រាស់ ១តឹកដែរ ដាក់ដើមចេកហាលឱ្យស្ងួតឱ្យអស់ជាតិជ័រ ។ រីឯស្រទាប់ទី៤ សូមដាក់ដីដំបូក ឬក៏ភក់បាតបឹងវិញ ។ ស្រទាប់នេះ ត្រូវតែធ្វើឱ្យទេរទាបម្ខាង ។ កសិករត្រូវបូមទឹកដាក់ស្រទាប់ខាងទាប រួចរកកំប្លោកតូចៗដាក់លើទឹក ។ បើទឹកស្អុយត្រូវផ្លាស់ចេញ ។

**ការដាក់ពូជ និងឱ្យចំណី**

កសិកររកពូជកូនអន្ទង់ដែលជាប់លប ឬទ្រូ ទើបបានល្អ ។ ក្នុងអាងមួយម៉ែត្រការ៉េ គឺត្រូវដាក់កូនអន្ទង់ពី៤០ ទៅ៦០ក្បាល ដាច់ខាតត្រូវឱ្យពួកវាមានទំហំប៉ុនៗគ្នា ដើម្បីកុំឱ្យពួកវាស៊ីគ្នា ។ កសិករត្រូវដាក់ចំណីឱ្យអន្ទង់ស៊ីយ៉ាងទៀងទាត់រៀងរាល់ថ្ងៃ ។ចំពោះបរិមាណចំណី ត្រូវមើលទៅលើសភាពជាក់ស្តែង បើវាស៊ីអស់ត្រូវថែម បើវាស៊ីនៅសល់ច្រើនពេក ត្រូវកាត់បន្ថយ ។ ចំណីរបស់វា មានដូចជាខ្យង ពោះមាន់ពោះជ្រូកស្ងោឆ្អិន ជន្លេន ត្រីចង្វារ កំពឹស ។ កសិករក៏អាចដាក់បបរកន្ទក់ ត្រកួន ស្លឹកដំឡូងជ្វា បន្លែផ្សេងៗ ចុងអង្ករស្លឹកកន្ទំថេត លាយបញ្ចូលគ្នាឱ្យពួកវាស៊ីបានដែរ ។

**វិធីសាស្ត្រមួយចំនួនទៀតដើម្បីបង្កើនទិន្នផល**

កសិករត្រូវឧស្សាហ៍សង្កេតទឹក និងភក់ ។ ខែដំបូង គាត់ត្រូវដូរទឹកក្នុង ២អាទិត្យ ម្តង ។ ចាប់ពីខែទីពីរឡើង គាត់ត្រូវប្តូរទឹក មួយអាទិត្យម្តង ហើយបើភក់មានក្លិនស្អុយ ត្រូវផ្លាស់ប្តូរផ្នែកខាងលើចេញ ។ កសិករក៏ត្រូវបំបែកកូនអន្ទង់តូចៗ ដាក់ចិញ្ចឹមកន្លែងផ្សេងប្រការកុំឱ្យអន្ទង់ធំស៊ីអន្ទង់តូច ។ កសិករគួរធ្វើអាងឱ្យបានទូលាយដើម្បីដាក់ជន្លេនចិញ្ចឹមជាចំណីអន្ទង់ ។ កសិករត្រូវធ្វើគម្របព្រួលឬស្សីដាក់គ្របពីលើអាងដើម្បីការពារអន្ទង់ពីសត្វផ្សេងៗ គឺដូចជាកណ្តុរ ឆ្មារ ពស់ បក្សី ចូលស៊ីអន្ទង់ ។ បើកសិករថែទាំបានល្អ រយៈពេល ៩ខែ អន្ទង់ មួយក្បាលអាចមានទម្ងន់ពី ៣ ទៅ ៦ខាំ ។

**ជាត សំភី**

**សិក្សាកសិកម្ម**

**ប្រសិនបើប្រិយមិត្តមានបំណងចង់សិក្សាអំពីវិធីសាស្ត្រ ឬបច្ចេកទេសខាងកសិកម្មគ្រប់ប្រភេទ ដូចជាការចិញ្ចឹមសត្វ ឬដាំដំណាំផ្សេងៗ គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅ សេដាក ឬបុគ្គលិកសេដាកអាចទៅបង្រៀនដល់ទីកន្លែងផ្ទាល់ដោយគិតក្នុងតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០២៣ ៨៨០ ៩១៦។**



# រលាកថ្លើម B

**សុខភាព គឺជាបញ្ហាសំខាន់។ ការយកចិត្តទុកដាក់បន្តិចបន្តួចក្នុងការស្វែងយល់ អាចធ្វើឱ្យបងប្អូនប្រជាពលរដ្ឋចៀសផុតពីជំងឺថ្លើមប្រភេទ B ដែលជួនកាលជំងឺនេះអាចជាសះស្បើយដោយខ្លួនឯង ឬមួយអាចវិវត្តន៍ទៅជាគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិតបាន។**

តាមប្រសាសន៍លោកវិន សំណាង ដែលជាអ្នកសម្របសម្រួលវេជ្ជសាស្ត្រប្រចាំនៅអង្គការក្តីសង្ឃឹមថ្មីសម្រាប់កុមារកម្ពុជាបានធ្វើការរៀបរាប់ប្រាប់ឱ្យដឹងថា :

ជំងឺថ្លើមប្រភេទ B ជាជំងឺមួយដែលធ្វើឱ្យរលាកសាច់ថ្លើម និងនាំដល់ការវិវត្តន៍ទៅជាជំងឺមហារីកថ្លើម ។ ជំងឺគឺបង្កឡើងដោយវីរុសហៅថា វីរុសរលាកថ្លើម B ។ ជំងឺរលាកថ្លើម B គឺមានលក្ខណៈឆ្លងដូចជាជំងឺអេដស៍ដែរ មានដូចជាឆ្លងតាមរយៈការរួមភេទ ការចាក់បញ្ចូលឈាមដែលមានផ្ទុកវីរុស ការប្រើរបស់មុតស្រួច ចាក់ទម្លុះស្បែករួមគ្នា ការប៉ះពាល់សារធាតុរាវនៃអ្នកផ្ទុកមេរោគ ឬក៏ឆ្លងពីម្តាយទៅកូននៅពេលមានផ្ទៃពោះជាដើម-ល-។

ជំងឺនេះ វាចែកចេញជាពីរប្រភេទ គឺរលាកថ្លើម B ស្រួចស្រាវ និងរលាកថ្លើមរ៉ាំរ៉ៃ ។ ចំពោះរលាកថ្លើម B ស្រួចស្រាវ ក្រោយពីវីរុសឆ្លងចូលក្នុងខ្លួនហើយ នឹងបង្កឱ្យឈឺភ្លាមៗ ។ អ្នកជំងឺលឿងស្បែកឈឺសាច់ដុំ ឈឺពោះ ឈឺសន្លាក់ អស់កម្លាំង មិនឃ្លានអាហារ ក្អួតម្តងម្កាល ស្រកគីឡូ ឬក្តៅខ្លួន-ល-។ ផ្ទុយទៅវិញ ជំងឺរលាកថ្លើម B រ៉ាំរ៉ៃ មិនបញ្ចេញរោគសញ្ញាឈឺខ្លាំងឱ្យឃើញភ្លាមទេ គឺវាវិវត្តន៍រលាកម្តងបន្តិចៗរហូតដល់សាច់ថ្លើមខូច ក្រិនថ្លើម ឬមហារីកថ្លើម រហូតធ្វើឱ្យអ្នកជំងឺបាត់បង់ជីវិត ឬក្លាយជាអ្នកផ្ទុកមេរោគ ។

ប៉ុន្តែជួនកាលនៅពេលវីរុសថ្លើមប្រភេទ B ឆ្លងចូល ក្នុងខ្លួនមនុស្សហើយ វាក៏មិនធ្វើឱ្យប៉ះពាល់អ្វីទេ។ ខ្លួនមនុស្សអាចបង្កើតប្រព័ន្ធស៊ាំបានដោយខ្លួនឯង ដែលធ្វើឱ្យវីរុសមិនអាចបង្កការគ្រោះថ្នាក់អ្វីឡើយ ។ ទោះជាយ៉ាងនេះ លោកវេជ្ជបណ្ឌិតវិន សំណាង បានគូសបញ្ជាក់ថា បើសិនជាបងប្អូនសង្ស័យថា ខ្លួនមានជំងឺរលាកថ្លើម B ស្រួចស្រាវឬរ៉ាំរ៉ៃ សូមបងប្អូនគួរទៅពិនិត្យធ្វើតេស្តឈាមដើម្បីរកមេរោគរួចសូមទៅជួបវេជ្ជបណ្ឌិតឯកទេសជំនាញខាងជំងឺនេះដើម្បីទទួលការព្យាបាលឱ្យបានត្រឹមត្រូវ ពីព្រោះជំងឺនេះមានការពិបាកព្យាបាលណាស់ បើវាឱ្យផលប៉ះពាល់ហើយនោះ ។

**ជាត សំភី**



លោកវេជ្ជបណ្ឌិតវិន សំណាង នៅមន្ទីរពេទ្យជ័យជម្នះខេត្តកណ្ដាល

Photo: P. Samphy

**ការបង្ការជំងឺ**

**យើងគប្បីចេះយកចិត្តទុកដាក់ចំពោះសុខភាពដោយមានអនាម័យល្អ និងអាចទៅធ្វើតេស្តឈាមដើម្បីទទួលវ៉ាក់សាំងការពារឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួននៅទីកន្លែងដែលផ្តល់សេវាត្រឹមត្រូវ។**

September-2007 II.qxd 9/21/2007 2:56 PM Page 6



សព្វថ្ងៃនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកំពុងតែចំណាយអស់កម្លាំងកាយចិត្តលើផ្នែកអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ។ ការសិក្សាអប់រំជាតិពិតជាគោលដៅដ៏ចំបងមួយដែលគ្រប់ប្រទេសទាំងអស់កំពុងយកចិត្តទុកដាក់យ៉ាងសកម្ម។ បច្ចុប្បន្ននេះ សាលារៀន វិទ្យាស្ថាន មជ្ឈ-មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ បានរីកដុះដាលពាសពេញផ្ទៃប្រទេសដែលខុសប្លែកជាងប៉ុន្មានឆ្នាំមុន។ ជាងនេះទៅទៀត សូម្បីតែនៅក្នុងមន្ទីរឃុំឃាំងដែលមិនមាននរណាអើពើសោះ ក៏ឥឡូវនេះវិស័យអប់រំចំណេះដឹងទូទៅ ជាពិសេសផ្នែកអក្ខរកម្មបានទៅបំពេញសេចក្តីត្រូវការរបស់ពួកគេដែរ។ ឆ្នាំនេះរាជរដ្ឋាភិបាលបានសង្កត់ធ្ងន់ទៅលើប្រធានបទដ៏សំខាន់មួយគឺ "អក្ខរកម្មគឺជាសិទ្ធិមូលដ្ឋាន" ដោយកំណត់ច្បាស់ថា "អក្ខរកម្ម គឺជាកូនសោជួយឱ្យមានសុខភាពល្អ និងសុខុមាលភាព" ដែលសំដៅជួយឱ្យបុគ្គលម្នាក់ៗ និងសង្គមជាតិទាំងមូលឱ្យទទួលបាននូវសុភមង្គល និងភាពសម្បូររុងរឿងទៅថ្ងៃអនាគត។

# អនីតិជនទណ្ឌិត ទទួលបានការអប់រំអក្ខរកម្ម



Photo: Akeup

អនីតិជនជាទណ្ឌិតកំពុងតែក្រេបជញ្ជក់យកចំណេះដឹងយ៉ាងយកចិត្តទុកដាក់ ជាមួយក្តីសង្ឃឹមថា ពួកគេនឹងអាចសាងអនាគតថ្មីនៅពេលបានចាកចេញពីពន្ធនាគារ



Photo: Akeup

**ការផ្តល់ចំណេះដឹងដល់ទណ្ឌិត ទាំងចំណេះដឹងទូទៅ ឬចំណេះដឹងជំនាញ គឺជាសកម្មភាពមួយដែលត្រូវយកចិត្តទុកដាក់ ពីព្រោះជាមួយនិងចំណេះដឹងទាំងនេះ ទណ្ឌិតនឹងអាចយកទៅប្រើប្រាស់ចិញ្ចឹមជីវិតដោយមិនធ្វើឱ្យមានកំហុសឆ្គងវិលមករកពន្ធនាគារម្តងទៀត**

ថ្ងៃទី៨ កញ្ញាកន្លងទៅនេះ គឺជាថ្ងៃដ៏ឧដុង្គឧត្តមមួយ ដែលប្រទេសកម្ពុជាបានប្រារព្ធនូវទិវាអក្ខរកម្ម ជាតិ និងអន្តរជាតិ ។ នៅឱកាសទិវានោះដែរ សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចេញសេចក្តីប្រកាសយ៉ាងឱឡារិកថា សូមឱ្យគ្រប់វត្តអារាម វិហារសាសនានានា មានចលនាព្រះសង្ឃ បព្វជិតសាសនាតាជីដូនជី លោកអាចារ្យ ដើម្បីចូលរួមជំរុញការងារអក្ខរកម្ម តាមរយៈការទេសនា ការឃោសនានៅតាមពិធីបុណ្យផ្សេងៗ ពីសារៈប្រយោជន៍នៃចំណេះដឹង និងសូមជួយរៀបចំនូវថ្នាក់រៀនអក្ខរកម្មនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ តាមវត្ត តាមព្រះវិហារសាសនា ដើម្បីជួយឱ្យបងប្អូន កូនចៅ ជាសាសនិក បានរៀនសូត្រគ្រប់ៗគ្នា ជាពិសេសអ្នកដែលមិនមានលទ្ធភាពរៀនសូត្រ ដើម្បីឱ្យបានរៀនសូត្រតាមគ្រប់រូបភាព និងដើម្បីជួយគាំទ្រ ឱ្យបានខ្លាំងក្លាដល់កិច្ចដំណើរការវិស័យអប់រំក្រៅប្រព័ន្ធ ជាពិសេសថ្នាក់អក្ខរកម្ម ។

ស្របនឹងសេចក្តីអំពាវនាវនេះដែរ នៅមន្ទីរឃុំឃាំងខេត្តកំពង់ចាមមានកម្មវិធីមួយដែលរៀបចំឡើង ឱ្យស្របទៅនឹងការយកចិត្តទុកដាក់យ៉ាងអស់ពីកម្លាំងកាយចិត្តរបស់សម្តេចនាយកនោះ គឺកម្មវិធីបណ្តុះបណ្តាលផ្នែកអក្ខរកម្មដល់ទណ្ឌិតនៃមន្ទីរឃុំឃាំងខេត្តនេះ ។ យោងទៅលើចំនុចនេះដែរ អ្នកស្រី ហង្ស ដារ៉ានី ដែលជានាយិកានៃអង្គការ CRM លើកម្មវិធីអរុណរះ មានប្រសាសន៍ទាក់ទងនឹងគោលបំណងនៃការអប់រំផ្នែកអក្ខរកម្ម ដល់អ្នកជាប់ឃុំឃាំង ទាំងនោះថា : "យើងមានកម្មវិធីអក្ខរកម្មជាមួយពួកគេ ដោយសារតែមានទណ្ឌិតមួយចំនួនមិនចេះអក្សរ ដែលធ្វើឱ្យពួកគេឃ្លាតឆ្ងាយពីសង្គម ។ ដោយពួកគេមិនអាចអានដំណឹងផ្សេងៗ ទាក់ទងនឹងការអប់រំផ្សេងៗ ទៀតជាដើម ។ ដូច្នេះហើយធ្វើឱ្យពួកគេងាយប្រព្រឹត្តនូវអំពើហិង្សានៅក្នុងគ្រួសារ និងសង្គមផងដែរ ។" អ្នកស្រីនាយិកាបន្តទៀតថា យើងមានបណ្ណាល័យដែលរៀបចំសម្រាប់ពួកគេ និងឱ្យពួកគេខ្ចីសៀវភៅសម្រាប់អានផងដែរ និងដើម្បីកុំឱ្យពួកគេគិតតែពីកំហុសរបស់ខ្លួន និងមានគំនិតសងសឹក ឬប្រព្រឹត្តអំពើអ្វីមួយខុសច្បាប់ទៀតតែប៉ុណ្ណោះ ។ អ្នកស្រីក៏ឱ្យដឹងបន្ថែមទៀតថា តាមពិតគោលដៅសំខាន់របស់យើងផ្តោតទៅលើអ្នកជំងឺអេដស៍ កុមារកំព្រា និងអ្នកក្រីក្រ ប៉ុន្តែដោយមើលឃើញថានៅក្នុងពន្ធនាគារ គឺជាកន្លែងមួយដែលពិបាកចេញចូល យើងក៏ចង់ឱ្យទណ្ឌិតមានភាពកក់ក្តៅនិងសេចក្តីស្រឡាញ់ពីអ្នកខាងក្រៅ ។ ដូច្នេះយើងសុំបង្កើតកម្មវិធីនេះសម្រាប់ពួកគេ ។ កំពុងដើរត្រួតពិនិត្យមើលសកម្មភាពរបស់ប្អូនៗ ជាអ្នកទោស ដែលកំពុងអង្គុយក្នុងថ្នាក់រៀនមួយដែលរៀបចំដោយមន្ទីរឃុំឃាំង លោកកែវ សំបូរ ដែល ជាអនុការិយា-ល័យអប់រំកែប្រែនៅពន្ធនាគារខេត្តកំពង់ចាម មានប្រសាសន៍ថា : "កម្មវិធីអក្ខរកម្មនេះ គឺយើងបានផ្តោតសំខាន់ ព្រោះថា ភាគច្រើនទណ្ឌិត និងពិរុទ្ធជនភាគច្រើនស្ថិតនៅក្នុងវ័យសិក្សា ប៉ុន្តែនៅពេលដែលពួកគេមកជាប់ឃុំឃាំងនៅទីនេះ ពួកគេក៏បានបាត់បង់ឱកាសក្នុងការសិក្សា ។ ដូច្នេះយើងត្រូវផ្តោតជាសំខាន់បំផុតចំពោះពួកគេក្នុងការផ្តល់ការអប់រំបណ្តុះបណ្តាល ដើម្បីឱ្យពួកគេទោះបីជាស្នាក់នៅទីនេះ ក៏មានឱកាសសិក្សាផងដែរ ដែលធ្វើឱ្យពួកគាត់ចេះអាន និងចេះសរសេរ ។ បន្ទាប់មកពួកគេអាចស្វែងយល់អំពីអ្វីដែលខុស និងអ្វីដែលត្រូវ ។ នេះគឺជាទិសដៅសំខាន់បំផុត ដែលមន្ទីរឃុំឃាំងរបស់យើងផ្តោតអារម្មណ៍ ។ លោកក៏បានឱ្យដឹងអំពីអត្ថប្រយោជន៍នៃកម្មវិធីថា ចំពោះការអប់រំនេះ ខ្ញុំយល់ថា វាផ្តល់ផលប្រយោជន៍ជាច្រើនដល់ទណ្ឌិត ដូចជា នៅពេលដែលពួកគេចូលមកទីនេះ ពួកគេបានបាត់បង់ការរៀនសូត្រនៅខាងក្រៅ ហេតុនេះហើយ យើងត្រូវបំពេញនៅចំនុចនេះឱ្យពួកគេវិញ ដោយធ្វើការអប់រំដល់ពួកគេ ដើម្បីបង្កើនការចេះដឹងឱ្យដល់ពួកគេ ដើម្បីកុំឱ្យពួកគេមាននូវភាពអវិជ្ជាកាន់តែខ្លាំងនៅពេលដែលចេញចាកពីទីនេះទៅ ។" លោកក៏បន្តទៀតថា លោក និងមន្ត្រីដទៃទៀតនៅមន្ទីរឃុំឃាំង សង្ឃឹមថាក្រោយពីពួកគេបានចាកចេញពីទីនេះ ពួកគេនឹងកែប្រែខ្លួន ដោយអាចប្រកបការងារ ឬអាចសម្របខ្លួនរស់នៅក្នុងសង្គមបានដោយងាយស្រួលដោយចេះដឹងចេះពិចារណា ដឹងខុសដឹងត្រូវនៅក្នុងការរស់នៅ ។ លោកកែវ សំបូរ ឱ្យដឹងបន្ថែមដែរថា ការបណ្តុះបណ្តាលផ្នែកអក្ខរកម្មនៅក្នុងពន្ធនាគារខេត្តកំពង់ចាមនេះ បានបង្កើតឡើងតាំងពីឆ្នាំ២០០៣មក ដោយសរុបទាំងអស់បានប្រហែលជាង ១២វគ្គមកហើយ ដោយនៅក្នុងនោះមួយវគ្គៗមានសិស្សជាអ្នកទោសប្រមាណជាជាង២០នាក់ទៅដល់៣០នាក់ ។

ក្រោយសម្រាកពីបង្រៀន លោកគ្រូម៉ក់ ឆៃដារ៉ា គ្រូស្ម័គ្រចិត្តមកពីកម្មវិធីអរុណរះរបស់អង្គការ CRM មានប្រសាសន៍ថា ជាធម្មតាយើងដឹងហើយថា ប្រសិនបើមនុស្សចេះអក្សរងាយស្រួល នឹងខិលតែបើមនុស្សដែលមិនចេះអក្សរ គឺងាយស្រួលនឹងគេល្បួង ។ ដូច្នេះបើសិនយើងឱ្យគេចេះ គេនឹងមានជំហរយ៉ាងមាំមួនចំពោះអ្នកដទៃដែលមានបំណងមិនល្អទៅលើគេ ។ ម្យ៉ាងទៀតបើគេចេះ ពេលគេរួចពីទោស គេក៏អាចបង្រៀនកូនៗ ប្អូនៗ ឬអ្នកដែលមិនចេះអក្សរបានខ្លះៗដែរ ។ "តាមទស្សនៈវិស័យខ្ញុំ ខ្ញុំជឿថាមានទណ្ឌិតជាច្រើននាក់នៅក្នុងចំណោមអ្នកដែលបានរៀន គឺអាចយកចំណេះទៅប្រើប្រាស់បាន ប៉ុន្តែបើគេពុំអាចយកទៅប្រើជាមួយនឹងសហគមន៍ធំៗ ឬតាមកន្លែងណាមួយបាននោះ គេក៏អាចប្រើប្រាស់នៅក្នុងគ្រួសារបាន ។" នេះគឺជាជំនឿជឿជាក់របស់លោកគ្រូដារ៉ា ។

ទាក់ទងទៅនឹងភាពជឿជាក់នេះផងដែរ លោកសំបូរ បានបង្ហាញឱ្យឃើញថា ការបណ្តុះបណ្តាលនេះគឺមានលទ្ធផលល្អចំពោះពួកគេ ដោយសារយើងពុំបានឃើញមានអ្នកដែលបានសិក្សាជាមួយកម្ម-វិធីនេះត្រឡប់ចូលមកទីនេះម្តងទៀតនោះទេ មានតែអ្នកដែលមិនបានរៀនសូត្រទេដែលត្រលប់មកទីនេះម្តងទៀត ។

កំពុងតែអង្គុយនៅគៀនជញ្ជាំង និងដៃកាន់ក្តារឈ្នួនយ៉ាងស្វាហាប់ លោកម៉ាត់ រី អាយុ ២៥ឆ្នាំ ជាសិស្សចាស់ និយាយថា លោករៀនជាមួយនឹងកម្មវិធីនេះបានជាង១ឆ្នាំមកហើយ ។ លោកប្រាប់ទៀតថា ការរៀននៅទីនេះមានការរីកចម្រើនល្អ ព្រោះថាវាអាចធ្វើឱ្យលោកចេះអាន ចេះសរសេរ ដែលពីមុន លោកមិនដែលបានស្គាល់អក្សរ ឬសាលារៀនសោះ ។ ក្នុងទឹកមុខស្រពោន និងខ្នងផ្អែកទៅលើជញ្ជាំង លោកម៉ាត់ រី បង្ហាញពីអារម្មណ៍មួយយ៉ាងមុតមាំថា : "ការសិក្សានៅទីនេះផ្តល់អត្ថប្រយោជន៍ចំពោះខ្ញុំយ៉ាងខ្លាំង ព្រោះខ្ញុំអាចចេះអាន និងសរសេរបានដូចអ្នកដែលបានរៀននៅឯសាលាដែរ ។" អ្នកទោសរូបនេះបន្តទៀតថា ការបង្រៀនរបស់គ្រូ គឺមានលក្ខណៈល្អដែរ ដោយគ្រូយកចិត្តទុកដាក់ ខិតខំព្យាយាមបង្រៀនដោយប្រុងប្រយ័ត្ន និងធ្វើការពន្យល់យ៉ាងអស់ពីសមត្ថភាពដោយធ្វើយ៉ាងណាឱ្យពួកគាត់ចេះ ។ លោកជាអ្នកទោសដែលត្រូវជាប់ឃុំឃាំងរយៈពេល៣ឆ្នាំកន្លះ ដោយសារជាប់ចោទពីបទចោរកម្មពាក់ព័ន្ធនឹងការទិញលក់ម៉ូតូ ។ លោកម៉ាត់ រី មានគម្រោងសម្រាប់ជីវិតរបស់គាត់រួចហើយដោយនៅពេលដែលលោកចេញពីមន្ទីរឃុំឃាំង លោកនឹងប្រកបអាជីវកម្មផ្ទាល់ខ្លួនមួយនៅផ្ទះរបស់លោក ។

ចំណែកកុមារាអឿង សៅ អាយុ១៥ឆ្នាំ ហាក់ដូចជាមានការស្តាយក្រោយចំពោះទង្វើរបស់ខ្លួន ជាពិសេសចំពោះការសិក្សា ។ កុមារាដែលមានរូបរាងកាយស្គមស្គាំងរូបនេះ បានដើរផ្លូវខុសទៅរកអំពើមួយ ដែលសង្គមស្អប់ខ្ពើម ដោយកុមារារូបនេះ គឺត្រូវជាប់នៅក្នុង ▪▪▪

**មន្ទីរឃុំឃាំងខេត្តកំពង់ចាម**

**តាមរយៈលោក កែវ សំបូរ អនុការិយាល័យអប់រំកែប្រែនៅពន្ធនាគារខេត្តកំពង់ចាមបានឱ្យដឹងថា មន្ទីរឃុំឃាំងក្នុងខេត្តកំពង់ចាមមានពីរ គឺមួយនៅក្នុងភូមិជីរ៉ូ២ ឃុំទន្លេបិទ នៅស្រុកត្បូងឃ្មុំ ដែលមានអ្នកទោសជាង ៥០០នាក់ ក្នុងនោះមានស្រីចំនួនជាង ២០នាក់។ មួយទៀតនៅជិតព្រំប្រទល់ប្រទេសវៀតណាមដែលមានឈ្មោះថា T៥ មានអ្នកទោស៥០នាក់ ដែលជាអ្នកទោសកម្រិតធ្ងន់ និងសុទ្ធតែជាមនុស្សប្រុស។**



Photo: Akeup

លោកគ្រូអក្ខរកម្មបង្ហាញអក្សរឱ្យសិស្សអានតាមនៅក្នុងពន្ធនាគារ

September-2007 II.qxd 9/21/2007 2:56 PM Page 8



... មន្ទីរឃុំឃាំងនេះរហូតដល់ទៅ៥ឆ្នាំ។ អឿង សៅ ក៏និយាយដោយអោនមុខចុះថា: "កាលមិនទាន់មកទីនេះ ខ្ញុំរៀនថ្នាក់ទី១"។ សៅ បន្តទៀតថា ការសិក្សាមានសារៈសំខាន់ណាស់ ពីព្រោះវាធ្វើឱ្យគេចេះដឹងច្រើន ហើយនៅពេលដែលគេចេញពីទីនេះ រូបគេក៏នឹងបន្តការរៀនទៀត។ "ខ្ញុំចង់រៀនភាសាអង់គ្លេស ពីព្រោះវាងាយស្រួលក្នុងការរកការងារធ្វើ។" អឿង សៅ និយាយដោយមានក្ដីសង្ឃឹម ប៉ុន្តែការរង់ចាំរបស់គេហាក់មានរយៈពេលយូរតទៅមុខទៀត។

លោកផាន បូរ៉ា អ្នកសម្របសម្រួលនៃកម្មវិធីរបស់អារុណរះ ក៏ឱ្យដឹងថា: "ការរៀនអក្ខរកម្មនេះមានផលប្រយោជន៍ច្រើន ពីព្រោះក្រោយពីពួកគេ បានរៀនហើយ អ្នកខ្លះក៏អាចសរសេរសំបុត្រទៅកាន់គ្រួសារ ទោះបីពួកគេសរសេរត្រូវ ឬមិនត្រូវក៏ដោយ។" អតីតគ្រូអក្ខរកម្មរូបនេះ ក៏បន្តថា យើងឃើញថា ការបណ្ដុះបណ្ដាលនេះជួយគេបានច្រើន ពិសេសផ្នែកផ្លូវចិត្ត ពីព្រោះនៅពេលដែលពួកគេជាប់ឃុំឃាំង មិនមានញាតិមិត្ត ឬឪពុកម្ដាយទៅសួរសុខទុក្ខពួកគេញឹកញាប់ទេ ព្រោះការសួរសុខទុក្ខត្រូវចំណាយថវិកាច្រើន។

នៅក្នុងសេចក្ដីអំពាវនាវនៃទិវាអក្ខរកម្មនេះដែរ សម្ដេចហ៊ុន សែន ក៏បានស្នើសុំឱ្យអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងសប្បុរសជនជាតិ និងអន្តរជាតិ សូមបង្កើននូវការយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រដល់សកម្មភាពអក្ខរកម្មទាំងសម្ភារៈ ថវិកា និង-បច្ចេកទេសដើម្បីជំរុញសកម្មភាពអប់រំក្រៅប្រព័ន្ធក្នុងប្រទេស ឱ្យមានដំណើរការល្អប្រសើរដូចជាប្រទេសនានានៅក្នុងតំបន់។ ម្យ៉ាងទៀត ប្រធានរោងចក្រ សហគ្រាស ក្រុមហ៊ុន សូមជួយជំរុញបើកថ្នាក់អក្ខរកម្ម ឬថ្នាក់បំប៉នមុខជំនាញផ្សេងៗ ដល់បងប្អូនកម្មករកម្មការិនី ដែលជាប្រយោជន៍ដល់ម្ចាស់រោងចក្រសហគ្រាសផង។


Photo: Akeup
ទោះជាយ៉ាងណា ក៏ទណ្ឌិតសប្បាយរីករាយនឹងទទួលចំណេះដឹងថ្មី

រីឯសិស្សវិទ្យាល័យ និងនិស្សិតនានាទាំងគ្រឹះស្ថានសាធារណៈ និងទាំងគ្រឹះស្ថានឯកជន ក៏សូមចូលរួមសហការគ្នាដោយស្ម័គ្រចិត្ត និងយ៉ាងសកម្មក្នុងសកម្មភាពអក្ខរកម្មនេះ ទាំងនៅតាមវត្តអារាម ទីកន្លែងផ្សេងៗ និងមូលដ្ឋាននានានៅទូទាំងប្រទេសទាំងមូល។

**អាគីប**

### អក្ខរកម្មកុមារ

**យោងតាមរបាយការណ៍របស់ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានឱ្យដឹងថា មានកុមារនៅទូទាំងប្រទេសដែលកំពុងសិក្សាចំនួនពីរលាននាក់កន្លះ ហើយកុមារដែលបានបោះបង់ចោលការសិក្សាក្នុងមួយឆ្នាំៗមានចំនួន ២៥ ម៉ឺននាក់។ របាយការណ៍នេះ ក៏បានបង្ហាញឱ្យដឹងទៀតថា អត្រានេះមានការថយចុះ បើប្រៀបធៀបកាលពីឆ្នាំមុន។ ចំណែកកុមារមិនបានចូលរៀននៅទូទាំងប្រទេសវិញមានចំនួនរហូតដល់ ២៤៧ ២៥០នាក់។**

## អក្ខរជនកំពុងទាមទារនូវការយកចិត្តទុកដាក់


Photo: L. Sovanna

**ក្នុងអត្ថន័យដ៏ពេញលេញនៃទស្សនទាន គឺមានប្រជាជនត្រឹមតែ ៣៦% ប៉ុណ្ណោះ ដែលអាយុរបស់ពួកគេលើសពី ១៥ឆ្នាំ ជាអក្ខរជនវិជ្ជាជីវៈ។ ចំណែកប្រជាជនចំនួនប្រមាណ ២៧%ផ្សេងទៀត ត្រូវបានគេចាត់ទុកថា ជាជនដែលមានចំណេះដឹងស្មើនឹងពាក់កណ្ដាលអក្ខរកម្ម។ ដោយឡែកប្រជាជន ៣៧% ដែលនៅសល់ គឺជាអក្ខរជនសុទ្ធសាធ។**

**អត្រាអក្ខរកម្មជាតិដែលនៅក្នុងនោះរួមមានរាប់ទាំងជនពាក់កណ្ដាលអក្ខរកម្មបុរសភេទ ត្រូវបានគេប៉ាន់ស្មានថា មានចំនួន ៧៩% ក្នុងខណៈដែលអត្រាអក្ខរកម្មជាស្ត្រីភេទវិញគឺមានតែចំនួន ៥៧%ប៉ុណ្ណោះ គិតជាមធ្យម។**

**ចំពោះបញ្ហាទាំងនេះ ក៏មានភាពខុសគ្នាជាសក្ដានុពលក្នុងប្រទេស ជាពិសេសរវាងតំបន់ជនបទ និងតំបន់ទីក្រុងផងដែរ។ ហើយយើងក៏បានសង្កេតឃើញនៅក្នុងនោះ មានជនជាតិភាគតិច ដែលត្រូវបានគេមើលឃើញថា ស្ថិតនៅក្នុងលំដាប់ទាបជាងគេបង្អស់។ ខេត្តមួយចំនួន ដែលរួមមានដូចជា ខេត្តស្ទឹងត្រែង មណ្ឌលគិរី ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងរតនគិរីជាដើម គឺអត្រាអក្ខរជនមានកម្រិតស្ថិតនៅក្រោមមធ្យមភាគជាតិនៅឡើយ (គឺស្ថិតក្នុងលំដាប់ឡើង ដែលមានចំនួនអក្ខរជនចាប់ពី២៣% ទៅ៥៦%)។**

**ក្នុងប្រទេសកម្ពុជា ក្រុមអាយុអាទិភាព ពី១៥-២៤ឆ្នាំ ត្រូវបានគេប៉ាន់ស្មានថា មានបុរសជាអនក្ខរជនចំនួន ៤០០ ០០០នាក់ និងស្ត្រីជាអនក្ខរជន មានចំនួន ៧០០ ០០០នាក់។ ក្រុមមនុស្សដែលមានអាយុចាប់ពី២៥ ដល់៤៥ឆ្នាំ ត្រូវបានគេប៉ាន់ប្រមាណថា មាន១,២លាននាក់ គឺជាអនក្ខរជន។**

**ការបណ្ដុះបណ្ដាលសមត្ថភាពសម្រាប់អក្ខរកម្មវិជ្ជាជីវៈពេញវ័យក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះ ត្រូវបានគេប៉ាន់ថា បានធ្វើលើសិស្សប្រមាណ ៥០ ០០០នាក់ក្នុង១ឆ្នាំ។ លើសពីនេះទៅទៀត គ្រូអក្ខរកម្មតិចជាងពាក់កណ្ដាលគឺជាស្ត្រីភេទ ដែលចំនួននេះមានន័យថា មានការខ្វះខាតខាងតួនាទីគំរូសម្រាប់ស្ត្រីជាអនក្ខរជន។**

**ភាពក្រីក្រនៅតែបន្តចំពោះមនុស្សពេញវ័យ និងយុវជនដែលងាយរងគ្រោះដោយសារតែកម្រិតអក្ខរកម្មរបស់ពួកគេនៅទាប រួមនិងការយល់ដឹងពីស្ថានភាពជីវិតនៅខ្សោយ។ ចំណែកចំណេះដឹងពាក់ព័ន្ធទៅនឹងជំនាញពាក់ព័ន្ធរបស់ពួកគេនៅមានកម្រិត ដែលបានក្លាយទៅជាកត្តាបង្អាក់នៅក្នុងសមត្ថភាពរបស់ពួកគេក្នុងការចូលរួម និងទាញយកផលប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចសង្គមជាតិ។ ចំណេះដឹង និងជំនាញដែលទាមទារឱ្យមនុស្សត្រូវធ្វើការក្នុងបែបផែនសេដ្ឋកិច្ច "ថ្មី" ឬដែលទាមទារឱ្យមនុស្សត្រូវទាញយកផលប្រយោជន៍ពីទំនើបកម្មនៃសេដ្ឋ-កិច្ចកសិកម្មបែបប្រពៃណីនៅមានកម្រិតមួយនៅឡើយសម្រាប់យុវជន និងមនុស្សពេញវ័យដែលជាអ្នកមិនមែនអក្ខរជនវិជ្ជាជីវៈ។ អនក្ខរជនជាស្ត្រីកំពុងស្ថិតនៅក្នុងភាពប្រថុយប្រថាន ជាពិសេសចំពោះអត្រាកំណើតខ្ពស់ និងអត្រាមរណៈរបស់មាតា អំពីអំពើហិង្សាក្នុងគ្រួសារ អំពីការជួញដូរផ្លូវភេទ និងការឆ្លងរាលដាលនៃមេរោគអេដស៍។ ដោយសង្កេតឃើញពីបញ្ហានេះ ទើបសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការជំរុញកាន់តែខ្លាំងឡើងទៅលើការពង្រឹងផ្នែកបណ្ដុះបណ្ដាលជំនាញអក្ខរកម្មវិជ្ជាជីវៈនេះទៅដល់ប្រជាជនដែលរស់នៅកន្លែងទាំងឡាយណាដែលកំពុងជួបប្រទះនូវករណីទាំងនេះ និងកំពុងរស់នៅក្នុងលក្ខខណ្ឌមិនល្អ។**

**ផែនការថ្នាក់ជាតិសម្រាប់ការងារអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ**





**ភាពវេទនាតែងប៉ះពាល់ដល់ប្រជាជនកម្ពុជាដែលងាយរងគ្រោះ ដូចជាជនពិការដែលគ្មានលទ្ធភាពក្នុងការប្រកបការងាររដូចអ្នកដែលមានកាយសម្បទាគ្រប់គ្រាន់។ ប៉ុន្តែពេលខ្លះកង្វះខាតនេះបានជំរុញឱ្យបងប្អូនកាន់តែតស៊ូដើម្បីធ្វើការផ្គត់ផ្គង់ជីវភាពគ្រួសារ ទោះបីជាបងប្អូនជួបប្រទះការលំបាកវេទនាយ៉ាងណាក៏ដោយ។**

# ជនពិការនៅតែរងទុក្ខ និងខ្វះខាត


Photo: L. Sovanna
លោកឈិត ឡុច

នៅតាមផ្លូវលំតូចមួយ ដែលអមដោយវាលស្រែ និងផ្ទះប្រក់ស្បូវតូចៗខ្ពស់ផុតពីដី និងមានមនុស្សកំពុងប្រកបការងាររៀងៗខ្លួននៅក្នុងភូមិស្គន់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លោកច្រឹង ញញ កំពុងអង្គុយនៅលើរនាបគ្រែចាស់ក្នុងខ្ទមតូច មានដំបូលធ្លុះធ្លាយដែលមើលទៅមិនមែនជាកន្លែងស្នាក់នៅ សម្រាប់មនុស្ស តែវាជាកន្លែងមួយដ៏កក់ក្ដៅសម្រាប់គ្រួសារលោក។ អតីតទាហានរូបនេះមានសំណាងអាក្រក់ ដោយបានទទួលរងគ្រោះថ្នាក់ធ្លាក់ខ្លួនជាជនពិការជើងទាំងពីរតាំងពីឆ្នាំ១៩៩១មក។ ក្រសែភ្នែកសម្លឹងមើលទៅផ្ទះថ្មីដែលស្ថិតនៅពីក្រោយផ្ទះខ្ទម លោកមានប្រសាសន៍ថា: "ចាប់ពីពេលនេះតទៅ គ្រួសារខ្ញុំលែងពិបាក គ្មានកន្លែងជ្រកភ្លៀងទៀតហើយ។" លោកបន្តថា អង្គការចេអេសបានផ្ដល់នូវផ្ទះមួយខ្នងដល់គ្រួសារលោក ដែលប្រៀបដូចជាបានវត្ថុមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់គ្រួសាររបស់លោក។

និយាយរដឹនៗ អ្នកស្រីដួង រៀម អាយុ ៤៩ឆ្នាំ ភរិយាលោក ញញ មានប្រសាសន៍លាយទឹកភ្នែករលីងរលោងថា: "គ្រួសារខ្ញុំខ្វះខាតយ៉ាងខ្លាំង សូម្បីតែអង្ករក៏គ្មានហូបគ្រប់គ្រាន់ផង ពោលគឺរកមួយពេលសម្រាប់មួយពេលប៉ុណ្ណោះ។ ពេលខ្លះ ពួកយើងក៏គ្មានអ្វីហូបផង។" អ្នកស្រីបន្តថាប្ដីអ្នកស្រីពុំអាចធ្វើអ្វីបានច្រើនទេ។ ការងារស្ទើរតែទាំងអស់ត្រូវធ្លាក់មកលើអ្នកស្រី និងកូនប្រុសច្បង។ រៀងរាល់ថ្ងៃ អ្នកស្រីត្រូវចូលព្រៃចម្ងាយជាង ២គមពីផ្ទះ កាត់ស្បូវយកមកឱ្យប្ដីរបស់អ្នកស្រីអង្គុយក្រងជាកណ្ដាប់លក់ឱ្យគេ។


Photo: L. Sovanna
លោកច្រឹង ញញ

លោកវង្ស ធីម អ្នកសម្របសម្រួលនៃអង្គការ ចេអេស ប្រចាំខេត្តកំពង់ធំ មានប្រសាសន៍អំពីគ្រួសារលោកញញថា គ្រួសាររបស់ពួកគាត់ក្រីក្រលំបាកខ្លាំងណាស់។ លោកធីម បន្ថែមថា: "នៅពេលខ្ញុំមកជួបពួកគាត់ជាលើកដំបូង ខ្ញុំក៏មានការអាណិតអាសូរខ្លាំងមែនទែន។ពួកគាត់គ្មានអាហារថ្ងៃត្រង់ហូបឡើយ។ ហើយផ្ទះពួកគាត់មានសភាពចាស់ទ្រុឌទ្រោម គឺរកកលនឹងដួលរលំ។" ដោយឃើញបែបនេះ អង្គការចេអេសក៏សម្រេចធ្វើផ្ទះថ្មីមួយជូនពួកគាត់។

ចំណែក លោកមុំ សាន្ត អាយុ ៤៦ឆ្នាំ ដែលផ្លាស់ទីដោយសាររទេះរុញរយៈពេលជាង១០ឆ្នាំមកហើយ ដោយសារគ្រោះថ្នាក់នាពេលលោកធ្វើជាជាងសំណង់ និយាយថា: "ដោយសារអង្គការចេអេសជួយ ទើបលោកមានផ្ទះ និងរទេះរុញ ដែលកាត់បន្ថយការលំបាកលោកបានមួយកម្រិត។" លោកបន្ថែមថា អង្គការក៏បានផ្ដល់អង្ករ អាហារ ថ្នាំពេទ្យខ្លះទៀតផងដែរ។ លោកមុំ សាន្ត ត្រូវបានប្រពន្ធបោះបង់ចោលនៅពេលលោកធ្លាក់ខ្លួនពិការ។ តែសំណាងល្អ មានស្ត្រីម្នាក់បានស្ម័គ្រចិត្តមកបម្រើលោកក្នុងនាមជាភរិយាថ្មី។

អង្គុយនៅលើអង្រឹង ដែលមានប្រដាប់ប្រដាធ្វើកង់ និងឥវ៉ាន់លក់ដូរបន្តិចបន្តួចក្នុងតូបតូចមួយ លោកឈិត ឡុច អាយុ៤៥ឆ្នាំ ពិការតែហាក់ដូចជាមានសំណាងខ្ពស់ជាងគេ ពីព្រោះលោកមានមុខរបរ និងជំនាញច្បាស់លាស់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។លោកមានប្រសាសន៍ថា: "អូហ៎! ខ្ញុំពិបាកខ្លាំងណាស់ នៅពេលមិនទាន់មានរទេះ។ ខ្ញុំត្រូវរំកិលតាមផ្លូវ ចម្ងាយ៣០០ម ពីផ្ទះទៅចំការពីព្រោះជើងខ្ញុំទាំងពីរដាច់ដោយសារមីន។" លោកបន្តទៀតថា ប៉ុន្តែពេលនេះមិនសូវជាពិបាកទេ ដោយសារតែមានរទេះរុញ ដែលធ្វើឱ្យការផ្លាស់ទីមានភាពរហ័សជាងពីមុនបន្តិច។ បើយោងតាមប្រសាសន៍របស់លោក ជា ជាតិ ដែលជាប្រធានសង្គមកិច្ចខេត្តកំពង់ធំ បានឱ្យដឹងថា នៅក្នុងខេត្តកំពង់ធំនេះទាំងមូលមានជនពិការ ១៦៨០នាក់ ដែលពួកគេភាគច្រើនពិការតាំងពីសម័យសង្គ្រាមមកម្ល៉េះ។

**អាគីប**

### អង្គការចេអេស

**តាមរបាយការណ៍របស់អង្គការចេអេសកម្ពុជាប្រចាំនៅខេត្តកំពង់ធំបានឱ្យដឹងថា មានជនពិការចំនួន៣៤៤នាក់ហើយ ដែលអង្គការចេអេសបានជួយតាំងតែពីឆ្នាំ២០០៥មក ក្នុងខេត្តកំពង់ធំនេះ ដែលនៅក្នុងចំណោមនោះ មាន ១៥២នាក់ ពិការដោយសារជំងឺ និង១៩២នាក់ពិការដោយសារសង្គ្រាម និងជាន់មីន។ អង្គការចេអេសបានជួយបងប្អូនដូចជាផ្ដល់រទេះរុញ ថ្នាំពេទ្យ សម្លៀកបំពាក់ បង្រៀនជំនាញផ្សេងៗ ផ្ដល់សេវាកម្មបញ្ជូនពួកគាត់ទៅមន្ទីរពេទ្យពេលមានជំងឺឈឺស្កាត់ផ្សេងៗ និងជាពិសេសបានជួយកសាងនូវផ្ទះថ្មីៗ ជូនដល់ពួកគាត់ទៀតផងដែរ។ ក្នុងមួយឆ្នាំៗ អង្គការបានចំណាយថវិកាប្រមាណជាពី៥០០០ ទៅ៦០០០ ដុល្លារអាមេរិកសម្រាប់ដំណើរការគម្រោងការ។**

# អង្គការការីតាសកម្ពុជាបណ្តុះបណ្តាលបុគ្គលិកអំពីប្រព័ន្ធព័ត៌មាន

ដើម្បីលើកកម្ពស់នូវការងារអភិវឌ្ឍសហគមន៍កសិកម្ម អប់រំយុវជន និងផ្នែកផ្សេងៗជាច្រើនទៀត ឱ្យកាន់តែមានប្រសិទ្ធភាពប្រសើរឡើង អង្គការការីតាសកម្ពុជាបានរៀបចំនូវសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីគម្រោង និងបុគ្គលិករបស់ខ្លួនពីរបៀបទំនាក់ទំនងប្រកបដោយមានប្រសិទ្ធភាពតាមរយៈរបៀបប្រព័ន្ធព័ត៌មាន។

សិក្ខាកាមប្រមាណ ៣០នាក់ បានមកជួបជុំគ្នានៅការិយាល័យអង្គការការីតាសខេត្តសៀមរាបក្នុងរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី៣១ សីហា ដល់ថ្ងៃទី០១ កញ្ញា ដែលដឹកនាំដោយលោកប៉ាទ្រីច នីកូលសុន មកពីផ្នែកផ្សព្វផ្សាយព័ត៌មានអង្គការការីតាសពិភពលោក ក្រុងរ៉ូម។ លោកបានបង្រៀនដល់សិក្ខាកាមទាំងអស់ពីនៃការថតរូប និងរបៀបសរសេរព័ត៌មាន ជាពិសេសការសរសេរករណីសិក្សាឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

លោកនុត សំអុល អគ្គនាយកអង្គការការីតាសកម្ពុជា បានមានប្រសាសន៍ថា នេះជាលើកទី១ ដែលការីតាសកម្ពុជារៀបចំសិក្ខាសាលាពីប្រព័ន្ធផ្សព្វផ្សាយ។ លោកអគ្គនាយកបន្តថា ដោយមើលឃើញពីកង្វះខាតនូវការសរសេរពីពត៌មានផ្សេងៗ ដែលទាក់ទងនឹងកម្មវិធីនៃអង្គការការីតាសកម្ពុជា ទើបមានបង្កើតនូវកម្មវិធីនេះឡើងដោយសង្ឃឹមថា បន្ទាប់ពីសិក្ខាសាលានេះ បុគ្គលិកជាសិក្ខាកាមទាំងអស់ក៏នឹងមានជំនាញក្នុងការសរសេរ និងថតរូបបានប្រសើរជាងមុន។ លោកនុត សំអុលបានបញ្ជាក់ទៅកាន់សិក្ខាកាមថា: "ការសរសេរ និងថតរូបវានឹងមិនមានការលំបាកនោះទេ បើសិនអ្នកទាំងអស់គ្នាខិតខំយកចិត្តទុកដាក់នោះ។"

ង៉ែត ធារី ជាសិក្ខាកាមមួយរូបបានប្រាប់ឱ្យដឹងថា: "ខ្ញុំចាប់អារម្មណ៍លើកម្មវិធីនេះ ទោះបីជាវាពុំមែនជាថ្នាក់មូលដ្ឋានគ្រឹះក៏ដោយ ព្រោះខ្ញុំបានរៀនជាមួយគ្រូដែលមានបទពិសោធន៍ និងមានជំនាញច្បាស់លាស់ មកពីប្រទេសក្រៅ"។ ធារីក៏បានបន្តដោយលាយនឹងសម្លេងសើចតិចៗថា នាងពុំអាចយកទៅអនុវត្តបានទាំងអស់នោះទេ តែនាងអាចរីកចម្រើននៅលើចំនុចខ្លះៗ ដែលនាងមិនធ្លាប់បានដឹងពីមុនមក។



Photo: L. Sovanna

ចំណែកលោក អៀង ចាន់ ជាបុគ្គលិកអង្គការការីតាសប្រចាំនៅខេត្តបាត់ដំបងមានចំណាប់អារម្មណ៍ក្នុងកម្មវិធីនោះដែរថា លោកធ្លាប់បានសរសេរអត្ថបទខ្លះៗ តែលោកពុំដឹងថា ខុស ឬត្រូវ តាមក្បួន ឬសមតាមទម្រង់នៃព័ត៌មានឬទេ។ ប៉ុន្តែនៅពេលនេះ លោកកាន់តែដឹងច្បាស់ពីការសរសេរនេះ។ លោកបន្តថា កម្មវិធីនេះជាការបំពេញបន្ថែមនូវការខ្វះចន្លោះ និងចំនុចមួយចំនួនដែលលោកមិនធ្លាប់បានដឹងពីមុនមក។

**អាគីប**

# សាលាមត្តេយ្យនៃក្តីស្រលាញ់ភូមិថ្មពេជ្រ

**សាលាមត្តេយ្យមួយខ្នងមាន៣បន្ទប់ភ្ជាប់ជាមួយនិងបណ្ណាល័យ១បន្ទប់ផង ត្រូវបានសម្ពោធកាលពីព្រឹកថ្ងៃទី១៧ ខែកញ្ញា កន្លងទៅនេះ នៅក្នុងភូមិថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ កម្មវិធីនេះប្រព្រឹត្តទៅឡើងក្រោមអធិបតីភាពរបស់លោកបាន សេន តំណាងមន្ទីរអប់រំស្រុកត្បូងឃ្មុំ តំណាងអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។**

**លោកបូជាចារ្យអូមែរ តំណាងអភិបាលព្រះសហគមន៍ មានប្រសាសន៍ថា: "ព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យអប់រំ ដោយបានជួយកសាងសាលារៀន និងជួយឧបត្ថម្ភកុមារ និងយុវជន-នារី ខ្មែរតាំងពីថ្នាក់មត្តេយ្យរហូតសកលវិទ្យាល័យ ដោយយើងសង្ឃឹមថាពួកគេនឹងផ្លាស់ប្តូរប្រទេសកម្ពុជាឱ្យមានមុខមាត់ថ្មី។"**

**ដោយការអប់រំមានសារៈសំខាន់ លោកបាន សេន**



Photo: S. Philong

**តំណាងការិយាល័យអប់រំស្រុក មានប្រសាសន៍ក្រើនរំឭក និងអំពាវនាវដល់មាតាបិតា ដែលមានកូនក្រោមអាយុ៦ឆ្នាំ សូមឱ្យនាំពួកគេមកចុះឈ្មោះចូលរៀន និងទទួលការអប់រំនៅទីនេះឱ្យបានគ្រប់ៗគ្នា ដើម្បីអនាគតរបស់ពួកគេ និងប្រទេសជាតិ។**

**លោកសុក ឃី បូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ភូមិថ្មពេជ្រ មានប្រសាសន៍ក្នុងឱកាសនោះថា: "សាលានេះអាចកើតមានបានដោយមានការគាំទ្រពីសប្បុរសជនពីប្រទេសកូរ៉េ និងបងប្អូនដែលនៅទីនេះផងដែរ ហើយខ្ញុំសូមអរគុណដល់បងប្អូនទាំងអស់ក្នុងភូមិ ដែលបានជួយអស់ពីកម្លាំងកាយចិត្តក្នុងការកសាងសាលានេះ។"**

**រ៉ូ ប៉ូរ៉ា**

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក:**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់
បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
**Tel/Fax : (855) 23 224 120 ;**
**E-mail : csccambodia@gmail.com**
**Web: www.catholiccambodia.org**
**ក្រុមប្រឹក្សាភិបាល:** លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ។
**ចាងហ្វាងការផ្សាយ:** លោកលី សុវណ្ណា។
**រោងពុម្ព: ភ្នំពេញ។**

# ព្យាយាមនាំមកនូវជោគជ័យ

នៅវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ សន្តប្រាំងស្វ័រ ព្រះសហគមន៍កាតូលិកចំការទៀងនៅក្នុងឆ្នាំសិក្សា ២០០៦-២០០៧នេះ សិស្សវិទ្យាល័យនេះបានចូលរួមប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ ចំនួន ៣៣នាក់ ក្នុងនោះ មានស្រី ១១នាក់ ដែលទទួលបានជោគជ័យ ១០០ភាគរយ។ ក្នុងនោះសិស្សដែលបានទទួលនូវនិទ្ទេសC មានចំនួន៣នាក់ ស្រី១នាក់ សិស្សទទួលបាននិទ្ទេស D មានចំនួន ១៤នាក់ មានស្រី ៥នាក់ និងសិស្ស ដែលបាននិទ្ទេស E មានចំនួន ១៦នាក់ មានស្រី៤នាក់។ លទ្ធផលដ៏ប្រសើរនេះជាការចូលរួមទាំងអស់គ្នាទាំងសិស្ស និងលោកគ្រូ អ្នកគ្រូ ជាពិសេសការយកចិត្តទុកដាក់ របស់គណៈគ្រប់គ្រងសាលា។ លោកប៊ុច វិបុលនាយកវិទ្យាល័យនេះបានបញ្ជាក់ថា: "ទោះបីជាលទ្ធផលនៃការប្រឡងក្នុងឆ្នាំសិក្សា ២០០៦-២០០៧នេះ ទទួលបានលទ្ធផលល្អប្រសើរពិតមែន ប៉ុន្តែអ្វីដែលយើងត្រូវធ្វើបន្តគឺត្រូវមានការខិតខំប្រឹងប្រែងព្យាយាម និងមិនត្រូវភ្លេចអំពីកាតព្វកិច្ចរបស់ខ្លួនឡើយ។"

**យុន សំអាត**



# ពិធីសម្ពោធសាលាមិត្តភាព - Veronica School

នាព្រឹកថ្ងៃទី០៩ កញ្ញាកន្លងទៅនេះ នៅព្រះសហគមន៍អ្នកលឿងមានប្រារព្ធពិធីសម្ពោធសាលារៀនមិត្តភាព ឬហៅថា Veronica School ដែលប្រព្រឹត្តទៅនៅភូមិដើមគរ ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង។

សាលារៀននេះបង្ហាញពីទំនាក់ទំនងរវាងប្រជាជនខ្មែរ និងវៀតណាមនៅក្នុងភូមិដែលចេះរួបរួមគ្នាកសាងឡើង។ អ្នកគ្រូឈុន ខេមរ៉ា នាយកសាលាថ្មីនេះ មានយោបល់ថា: "សាលារៀននេះជាចំណងដ៏យ៉ាងសំខាន់ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាពរបស់ប្រជាជនក្នុងភូមិឱ្យកាន់តែរឹងមាំ ហេតុនេះហើយបានជាយើងដាក់ឈ្មោះសាលាមិត្តភាព - Veronica School។

លោកអូមែរ ហ្ស៊ីរ៉ាល់ដូ បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍អ្នកលឿង ពន្យល់ថា: "ឈ្មោះវេរ៉ូនីកានេះ គឺជាឈ្មោះនៅក្នុងប្រពៃណីដើមនៃគ្រីស្តសាសនា ដែលនិយាយពីស្ត្រីម្នាក់បានជូតព្រះភក្ត្ររបស់ព្រះយេស៊ូ ពេលកំពុងលីឈើឆ្កាង។ អាកប្បកិរិយារបស់ស្ត្រីម្នាក់នេះ បង្ហាញពីសេចក្តីអាណិតមេត្តាករុណាដល់អ្នកដទៃ ជាពិសេសដល់អ្នករងទុក្ខវេទនា។ នេះជាលក្ខណៈប្រពៃណីមួយដែលគ្រីស្តសាសនា និងព្រះពុទ្ធសាសនាបានអប់រំទូន្មានមនុស្សឱ្យដើរក្នុងផ្លូវល្អ។"

នៅក្នុងពិធីនេះ មានភ្ញៀវជាតិ និងអន្តរជាតិ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើនប្រមាណជាង ៣០០នាក់ ដែលមកចូលរួមសម្ពោធសាលារៀនមួយខ្នងដែលឧបត្ថម្ភដោយលោកបូជាចារ្យអូមែរ ហ្ស៊ីរ៉ាល់ដូ សប្បុរសជនពីប្រទេសសិង្ហបុរី បងស្រីដាយអាណា កោះ មូលនិធិជួយជនក្រីក្រនៅសហរដ្ឋអាម៉េរិក និងលោកបូជាចារ្យអាល់ប៊ែរត្ទូ។ លោកឡៃ យ៉ាំងហេង អ្នកគ្រប់គ្រងការសាងសង់សាលា មានប្រសាសន៍ថា: "ខ្ញុំមានសេចក្តីរំភើបរីករាយណាស់ ដែលឃើញក្មេងៗក្នុងភូមិមានសាលារៀន ហើយសង្ឃឹមថា ពួកគេនឹងមានអនាគតល្អគ្រប់ៗគ្នា។"

**ប៊ុង យ៉ិត**

Photo: S. Philong



បងស្រីដាយអាណា កោះ កាត់ខ្សែបូសម្ពោធសាលា

## អធិប្បាយព្រះបន្ទូល

## ថ្ងៃអាទិត្យទី ២៦ ក្នុងរដូវធម្មតា (ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០០៧)

### "អ្នករាល់គ្នាជាអ្នកមានអើយ! អ្នកនឹងត្រូវវេទនា!"

(លូកា ១៦,១៩-៣១)

នរណាក៏ដោយ ក៏ចង់មានប្រាក់ចាយគ្រប់គ្រាន់ និងក៏ចង់បានធូរធារដែរ! តែសម្រាប់ប្រទេសកម្ពុជាយើងនេះវិញក្រោយពីកើតអសន្តិសុខជាយូរឆ្នាំមកហើយនោះ ក៏នាំឱ្យមានអ្នកក្រីក្រជាច្រើន។ ប៉ុន្តែនៅថ្ងៃនេះ ព្រះយេស៊ូបានប្រៀនប្រដៅយើងតាមរបៀបប្លែកពីគ្រូធម្មតា ឬតាមរបៀបផ្សេងពីសេចក្តីរង់ចាំរបស់មនុស្សលោកទូទៅផង។ ព្រះអង្គរៀបរាប់ប្រស្នាមួយស្តីអំពីអ្នកមានស្តុកស្តម្ភ និងអ្នកសុំទានម្នាក់ ឈ្មោះឡាសារ។ តាមការពិត អ្នកមាននោះមិនមែនជាមនុស្សខិលខូចទេ គាត់ក៏មិនធ្វើបាបអ្នកក្រីក្រដែរ គាត់គ្រាន់តែមិនអើពើនឹងអ្នកក្រដែលដេកនៅមុខផ្ទះគាត់ប៉ុណ្ណោះ។ គាត់មិនរវីរវល់នឹងគេ!។ លុះដល់អ្នកទាំងពីរទទួលមរណភាពទៅ អ្នកមាននឹងត្រូវវេទនា រីឯអ្នកក្របានសេចក្តីសុខសាន្តវិញ។

ជាធម្មតាក្នុងគម្ពីរមានចែងថា អ្នកមានទទួលព្រះពរពីព្រះជាម្ចាស់ ហើយព្រះអង្គក៏ប្រៀនប្រដៅអ្នកណែនាំឱ្យធ្វើការបំបាត់ភាពក្រីក្រតោកយ៉ាកពីសង្គមដែរ។ ប៉ុន្តែក្នុងគម្ពីរព្យាការីក៏តែងតែស្តីបន្ទោសអ្នកមានដែលពឹងផ្អែកតែលើទ្រព្យសម្បត្តិរបស់ខ្លួនហើយមិនផ្ញើជីវិតលើព្រះជាម្ចាស់ទាល់តែសោះដែរ។ ព្រះយេស៊ូមានបន្ទូលដែរថា អ្នកមានត្រូវវេទនាពីព្រោះគេគេចវេះពីការសង្គ្រោះរបស់ព្រះអង្គ។ ម្យ៉ាងទៀតអ្នកមានមិនរវីរវល់នឹងអ្នកក្រប៉ុន្មានទេ។ ក្នុងអត្ថបទទី១ ព្យាការីអាម៉ូសក៏ស្តីបន្ទោសអ្នកមានយ៉ាងខ្លាំង ពីព្រោះគេមិនរវីរវល់នឹងវាសនាស្រុករបស់គេឡើយ។ អ្នកមាននឹងអ្នកក្រជាបងប្អូនបង្កើតពីព្រោះអ្នកទាំងពីរជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះបិតាតែមួយព្រះអង្គតែប៉ុណ្ណោះ។



ដូច្នេះនៅថ្ងៃនេះ យើងម្នាក់ៗត្រូវតែសួរខ្លួនឯងថា តើខ្លួនរកប្រាក់ចំណូលតាមរបៀបយ៉ាងដូចម្តេច? តើយើងរកបានដោយការជិះជាន់កេងប្រវ័ញ្ច ឬដោយរកស៊ីតាមយុត្តិធម៌ទេ? តើខ្ញុំយកចិត្តទុកដាក់នឹងអ្នកក្រជាងខ្លួនយ៉ាងណា? របៀបតបឆ្លើយនេះ បញ្ជាក់ថា ខ្លួនជាគ្រីស្តបរិស័ទបែបណា។

## ថ្ងៃអាទិត្យទី ២៧ ក្នុងរដូវធម្មតា (ថ្ងៃទី៧ តុលា ឆ្នាំ២០០៧)

### "សូមព្រះអង្គប្រទានជំនឿមកយើងខ្ញុំថែមទៀត"

(លូកា ១៧,៥-១០)

គ្រីស្តទូតសុំព្រះយេស៊ូប្រទានជំនឿឱ្យគេថែមទៀត គឺឱ្យពួកគេចេះផ្ញើជីវិតទាំងស្រុងទៅលើព្រះគ្រីស្តកាន់តែខ្លាំងឡើងៗ។ យើងជាគ្រីស្តបរិស័ទ ត្រូវប្រយ័ត្នចំពោះអត្ថន័យពាក្យ "ជំនឿ" និង "ខ្ញុំជឿ"។ ពាក្យទាំងនេះ មិនគ្រាន់តែមានន័យថា យើងសុខចិត្តទទួលយកសេចក្តីដែលព្រះយេស៊ូមានព្រះបន្ទូល ឬសេចក្តីដែលព្រះសហគមន៍ប្រៀនប្រដៅថាជាសេចក្តីពិតប៉ុណ្ណោះទេ គឺពាក្យទាំងនេះមានន័យទៀតថា ខ្ញុំសូមផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្ត ឬលើព្រះបិតា ខ្ញុំមិនពឹងផ្អែកលើ បុណ្យកុសល ឬលើខ្លួនផ្ទាល់ឡើយ។ ហេតុនេះហើយបានជា អ្នកជឿលើព្រះជាម្ចាស់អាចសម្រេចការអស្ចារ្យបាន ពីព្រោះមិនមែនខ្លួនប្រព្រឹត្តការអស្ចារ្យនោះទេ គឺព្រះជាម្ចាស់ឯណោះប្រព្រឹត្តវិញ។ ព្រះយេស៊ូយកឧទាហរណ៍មួយដ៏ហួសហេតុដើម្បីពន្យល់នូវសេចក្តីនេះ គឺអ្នកជឿអាចរើភ្នំទម្លាក់ក្នុងសមុទ្របាន។ នេះជារបៀបព្រះអង្គមានព្រះបន្ទូលបំផ្លើសដើម្បីឱ្យអ្នកស្តាប់ស្រួលយល់។

អ្នក "ជឿ" លើព្រះយេស៊ូក៏ប្រព្រឹត្តតាមបញ្ជារបស់ព្រះអង្គគ្រប់ពេលវេលា គឺប្រព្រឹត្តតាមវិន័យរបស់ព្រះអង្គដោយគ្មានសង្ឃឹមថា នឹងទទួលរង្វាន់ដោយបានប្រព្រឹត្តអំពើល្អនោះទេ។ អ្នករង់ចាំទទួលរង្វាន់ នៅតែពឹងលើបុណ្យកុសលដែលខ្លួនសន្សំនោះដដែល មិនទាន់ផ្ញើជីវិតទាំងស្រុងលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតាដែលស្រឡាញ់គេដ៏លើសលប់នោះនៅឡើយទេ។ យើងមិនទទួលការសង្គ្រោះដោយយើងប្រព្រឹត្តអំពើល្អនេះទេ គឺដោយសារយើងផ្ញើជីវិតលើព្រះបិតាវិញ។ អំពើល្អគឺគ្រាន់តែបញ្ជាក់ជំនឿរបស់យើង ដែលស្ម័គ្រដើរតាម និងប្រព្រឹត្តតាមសេចក្តីប្រៀនប្រដៅរបស់ព្រះយេស៊ូតែប៉ុណ្ណោះ ហើយតាមរយៈកិច្ចការទាំងនេះ នាំឱ្យយើងយល់ពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ជាព្រះបិតាកាន់តែខ្លាំងឡើងៗថែមទៀត។



**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!**

# អូណោស្តា : "យើងទាំងអស់គ្នាមានសមត្ថភាពអាចធ្វើកិច្ចការទាំងនេះបាន"



Photo: DR

**លោកស្រីអូណោស្តា កាពីណោ កើតនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៣៥ នៅប្រទេសអ៊ីតាលី ហើយបានទទួលមរណភាពថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៧ កន្លងទៅនេះនៅប្រទេសអ៊ីតាលី ដោយជំងឺធ្ងន់ធ្ងរ។**

លោកស្រីស្ម័គ្រចិត្តមកបម្រើការងារនៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៨០ តាមរយៈអង្គការស៊ីដសេ (CIDSE) ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការស្តារ និងអភិវឌ្ឍប្រទេសឡើងវិញ បន្ទាប់ពីមានសង្គ្រាមសម្លាប់ដ៏ឃោរឃៅ។ រយៈពេលនៃការបំពេញការងារ លោកស្រីបានយកអស់កម្លាំងកាយចិត្តបម្រើប្រជាជនកម្ពុជាដែលក្រីក្រ។ ទោះបីក្នុងពេលមានជំងឺ ដែលលោកស្រីត្រូវត្រឡប់ទៅប្រទេសអ៊ីតាលីនៅឆ្នាំ២០០២ ក៏លោកស្រីនៅបន្តសកម្មភាពជួយអ្នកក្រីក្រនៅប្រទេសកម្ពុជា ក៏ដូចជាប្រទេសផ្សេងៗទៀតផងដែរ រួមមាន ប្រទេសឥណ្ឌា និងប្រទេសវៀតណាមជាដើម គឺរហូតដល់ពេលលោកស្រីទទួលមរណភាព នៅឆ្នាំ២០០៧នេះ។

នៅក្នុងលិខិតជូនពរបុណ្យណូអែល ឆ្នាំ២០០៦ ជូនមិត្តសម្លាញ់ លោកស្រីបានសរសេរបញ្ជាក់ថា : "ចំពោះខ្ញុំពិបាកទទួលយកណាស់នៅពេលខ្ញុំឃើញប្រជាជន រងទុក្ខវេទនា និងស្លាប់ដោយសារសង្គ្រាម ភាពអត់ឃ្លាន ភេរវកម្ម និងអំពើហិង្សារបស់សង្គម ព្រមទាំងប្រព័ន្ធសេដ្ឋកិច្ចដែលកៀបសង្កត់ប្រជាជនក្រីក្រ និងដែលនាំឱ្យអ្នកមានរឹតតែមានឡើងៗ។ តែទុក្ខវេទនា និងអំពើហិង្សាទាំងនេះធ្វើឱ្យយើងអាចរកវិធី ឬសកម្មភាពណាមួយដើម្បីជួយសង្គ្រោះជីវិតមនុស្សបាន ទោះបីជាបានតែម្នាក់។" លោកស្រីបន្តនៅក្នុងលិខិតនោះថា: "យើងទាំងអស់គ្នាមានសមត្ថភាពអាចធ្វើកិច្ចការនេះបាន។"

នៅក្នុងអំឡុងពេលកំពុងមានជំងឺ និងសម្រាកព្យាបាលជំងឺនៅប្រទេសអ៊ីតាលី លោកស្រីអូណោស្តា បានបង្កើតមូលនិធិអប្បរាអនលូស រួមជាមួយមិត្តភក្តិរបស់លោកស្រី ដើម្បីប្រមូលថវិកា មកជួយប្រជាជននៅប្រទេសមួយចំនួនដូចជាកម្ពុជា វៀតណាម និងឥណ្ឌា។ កម្មវិធីដែលឧបត្ថម្ភដោយមូលនិធិអប្បរាអនលូសនៅប្រទេសកម្ពុជា មានដូចជាកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងកម្មវិធីអភិវឌ្ឍសហគមន៍ មានកម្មវិធីអប់រំកុមារជាដើម ដែលមានសកម្មភាពនៅក្នុងខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងរាជធានីភ្នំពេញ។

ក្នុងកិច្ចសម្ភាសន៍ជាមួយវិទ្យុអេប៊ីស៊ី (ABC, Australia) នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៨ លោកស្រីអូណោស្តា បានរំឭកឡើងវិញពីការវិលត្រលប់ចូលក្រុងភ្នំពេញរបស់ប្រជាជននៅឆ្នាំ១៩៨០។ លោកស្រីក៏បានបញ្ជាក់ថា : "ទីក្រុងភ្នំពេញគឺត្រូវបានបំផ្លាញស្ទើរទាំងស្រុង។ ប្រជាជនដើរចុះដើរឡើង ដើម្បីស្វែងរកញាតិសណ្តានខ្លួន។ អ្នកខ្លះទៀតកំពុងតែស្វែងរកអាហារ។ នៅតាមផ្លូវ សុទ្ធតែសំរាម និងព្រៃល្បោះ(...)។ ពេលនោះ យើងទាំងអស់គ្នាក៏បានខិតខំស្វែងរកមធ្យោបាយផ្សេងៗដើម្បីចិញ្ចឹមប្រជាជន ស្របពេលនោះដែរ យើងគ្មានប្រាក់សម្រាប់ធ្វើសកម្មភាពផ្សេងៗទៀតឡើយ"។ លោកស្រី ក៏បន្តថា : "អ្វីដែលខ្ញុំចាប់អារម្មណ៍គឺស្ត្រីវ័យក្មេងជាច្រើនមានផ្ទៃពោះ។ ខ្ញុំបានឮថា នៅក្នុងសម័យប៉ុលពត គ្មានអាហារគ្រប់គ្រាន់ និងត្រូវធ្វើការជាទម្ងន់ ស្ត្រី គ្មានកម្លាំងដើម្បីបង្កើតកូនឡើយ។ ប៉ុន្តែពេលនេះស្ត្រីអាចបង្កើតកូនបាន សម្រាប់ខ្ញុំនេះជាសញ្ញាមួយដ៏ល្អ ដែលបញ្ជាក់ថាសង្គមថ្មីកំពុងកើតឡើង ព្រោះថាជីវិតមនុស្សមានតម្លៃលើសអ្វីៗទាំងអស់។"

នៅក្នុងនាមព្រះសហគមន៍កាតូលិក នៅកម្ពុជា លោកបូជាចារ្យ អូមែរ សូមថ្លែងអំណរគុណចំពោះលោកស្រីអូណោស្តា និងក្រុម ដែលបានយកចិត្តទុកដាក់ជួយដល់ប្រជាជនកម្ពុជា។ យើងក៏សង្ឃឹមថា ផលផ្លែនៃកិច្ចការរបស់លោកស្រីនឹងស្ថិតនៅក្នុងចិត្តរបស់យើងជានិច្ច។ គំរូដ៏ល្អរបស់លោកស្រី នឹងឱ្យធ្វើយើងទាំងអស់គ្នាមានកម្លាំងចិត្តដើម្បីបំពេញបេសកកម្មនានាសម្រាប់ជូនឱ្យអ្នកក្រីក្រ។ យើងទាំងអស់គ្នាជឿជាក់យ៉ាងមុតមាំថា លោកស្រី នាពេលនេះ បានរួមរស់ជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខដោយរីករាយហើយ។

**អ្នកនាំសារ**

## កម្រោងព្រះសហគមន៍

- ថ្ងៃទី១៨-២១ កញ្ញា : សន្និបាតទូទាំងប្រទេសរបស់ក្រុមវិនសេន ឌឺ ប៉ូល មានចំនួន ៧០នាក់ចូលរួម ធ្វើឡើងនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី២១ កញ្ញា : លោកឪពុកសុកឃី ទទួលខុសត្រូវព្រះសហគមន៍សួងទៅវិស្សមកាលនៅកូរ៉េរយៈពេល ៤ខែ គឺរហូតដល់ថ្ងៃទី២១ មករា ឆ្នាំ២០០៨ ទើបត្រឡប់មកវិញ។
- ថ្ងៃទី២១ កញ្ញា : បុណ្យសន្តិតេរ៉េសានៃព្រះកុមារយេស៊ូ នៅព្រះសហគមន៍ចំណោម ភូមិភាគបាត់ដំបង។
- ថ្ងៃទី២៨-២៩ កញ្ញា : ពិធីបុណ្យកាន់បិណ្ឌ នៅព្រះសហគមន៍ចំណោម។
- ថ្ងៃទី៣០ កញ្ញា : មានសិក្ខាសាលាគ្រូអប់រំជំនឿ ចំនួន ២៥នាក់ នៅព្រះវិហារសន្តយ៉ូសែប-រាជធានីភ្នំពេញ។

## មណ្ឌលអ្នកជំងឺអេដស៍

បងប្រុសនៃក្រុមសាសនទូតមេត្តាករុណា !
"ផ្ទះនៃក្តីសង្ឃឹម" សូមជម្រាបដំណឹងបងប្អូនថា : "ផ្ទះនៃក្តីសង្ឃឹម" មានទទួលថែរក្សាអ្នកជំងឺអេដស៍បុរសដោយមិនគិតថ្លៃ។ បើបងប្អូនបានស្គាល់អ្នកជំងឺអេដស៍ជាបុរសដែលត្រូវការសេវាខាងលើ សូមទាក់ទងមកក្រុមបងប្រុសនៃក្រុមសាសនទូតមេត្តាករុណានៅភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោ ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ : ០១២ ៩៥៩ ៨១៨។

## សេវាកម្មជាទីគាប់ចិត្ត !

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងមានទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងនេះនឹងធ្វើក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទំនាក់ទំនងតាមទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។

មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៦ ថ្មី ដែលពិពណ៌នាអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង។ តម្លៃក្នុងមួយ ស៊ីឌីគឺ ៨ ០០០រៀលតែប៉ុណ្ណោះ។ ប្រសិនប្រិយមិត្តចាប់អារម្មណ៍ សូមទំនាក់ទំនងតាមទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។